ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

សេចក្តីព្រាង

ច្បាប់

ស្តីពី

កិច្ចការពារទិន្នន័យបុគ្គល

នៃព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី ខែ ឆ្នាំ២០២៥

អគារលេខ ១៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក
ខណ្ឌដូនពេញ រាជធានីភ្នំពេញ 120210

123 023 724 810
www.mptc.gov.kh

ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា១ .. គោលបំណង

ច្បាប់នេះកំណត់អំពីគោលការណ៍ វិធាន និងយន្តការគ្រប់គ្រងនៃការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលដោយមានការទទួលខុសត្រូវ តម្លាភាព និងប្រកបដោយក្រមសីលធម៌ ក្នុងគោលបំណងការពារសិទ្ធិរបស់ប្រជាជនទិន្នន័យ និងលើកកម្ពស់បរិយាកាសវិនិយោគ ការប្រកួតប្រជែង និងការអភិវឌ្ឍពាណិជ្ជកម្មជាតិ និងអន្តរជាតិក្នុងបរិបទនៃសេដ្ឋកិច្ចនិងសង្គមឌីជីថល។

មាត្រា២ .. វិសាលភាព

ច្បាប់នេះ ជាច្បាប់គោល ដែលមានវិសាលភាពអនុវត្តលើការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គល តាមរយៈមធ្យោបាយស្វ័យប្រវត្តិកម្ម ឬមិនស្វ័យប្រវត្តិកម្មដែលបង្កើតជាប្រព័ន្ធឯកសារដោយ៖

ក- បុគ្គលគ្រប់គ្រងទិន្នន័យនិងបុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យដែលមានទីតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ទោះបីក្នុងគោលបំណងអ្វីក៏ដោយ។

ខ- បុគ្គលគ្រប់គ្រងទិន្នន័យនិងបុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យដែលមានទីតាំងនៅក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងផ្តត់ផ្តង់ទំនិញឬសេវាឱ្យប្រជានទិន្នន័យឬតាមដានសកម្មភាពពាក់ព័ន្ធនឹងប្រជានទិន្នន័យដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ច្បាប់នេះមិនអនុវត្តចំពោះការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គល ដោយ៖

ក- អាជ្ញាធរសាធារណៈដែលបំពេញមុខងារក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឡើយ។

ខ- រូបវន្តបុគ្គលដែលធ្វើសកម្មភាពផ្ទាល់ខ្លួន ឬសកម្មភាពពាក់ព័ន្ធនឹងគ្រួសារតែប៉ុណ្ណោះ។

មាត្រា៣ .. និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

ជំពូកទី២
ស្ថាប័នមានសមត្ថកិច្ច

មាត្រា៤ .. ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍មានសមត្ថកិច្ចគ្រប់គ្រងកិច្ចការពារទិន្នន័យបុគ្គល និងមានភារកិច្ចដូចខាងក្រោម៖

ក- ធ្វើនិយ័តកម្ម សវនកម្ម និងត្រួតពិនិត្យកិច្ចការពារទិន្នន័យបុគ្គលស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

ខ- មានអំណាចបង្គាប់បុគ្គលគ្រប់គ្រងទិន្នន័យ និងបុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យឱ្យផ្តល់ទិន្នន័យបុគ្គលឬព័ត៌មានដែលចាំបាច់សម្រាប់បំពេញមុខងារនិងភារកិច្ចរបស់ខ្លួន។

គ- មានសិទ្ធិអាក់សេសរាល់ទិន្នន័យបុគ្គល និងព័ត៌មានដែលចាំបាច់សម្រាប់បំពេញមុខងារនិងភារកិច្ចរបស់ខ្លួន។

ឃ- ទទួលពាក្យបណ្តឹង និងផ្សះផ្សាវិវាទពាក់ព័ន្ធនឹងកិច្ចការពារទិន្នន័យបុគ្គល។

ង- លើកកម្ពស់ និងបញ្ជោបការយល់ដឹងអំពីកិច្ចការពារទិន្នន័យបុគ្គល។

ច- សហការ និងផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធនឹងកិច្ចការពារទិន្នន័យបុគ្គលជាមួយក្រសួង ស្ថាប័នជាតិ និងអន្តរជាតិ។

ឆ- តាមដានការវិវត្តនៃការងារពាក់ព័ន្ធនឹងកិច្ចការពារទិន្នន័យបុគ្គល។

ជ- គ្រប់គ្រងការផ្ទេរទិន្នន័យបុគ្គលឆ្លងដែន ដោយតាមដាន និងរឹតត្បិតឬអនុញ្ញាតឱ្យមានការផ្ទេរទិន្នន័យបុគ្គលឆ្លងដែន។

ឈ-អនុវត្តការកិច្ចផ្សេងៗទៀតតាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។

មាត្រា៥ .- អង្គភាពឧទ្ធរណ៍បន្ទុកកិច្ចការពារទិន្នន័យបុគ្គល

ក្នុងស្ថានភាពចាំបាច់ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍អាចស្នើសុំការសម្រេចរបស់រាជរដ្ឋាភិបាល ដើម្បីបង្កើតអង្គភាពទទួលបន្ទុកកិច្ចការពារទិន្នន័យបុគ្គល ដែលជានីតិបុគ្គលនៃនីតិសាធារណៈ។

ជំពូកទី៣
ការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គល

មាត្រា៦ .- គោលការណ៍នៃការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គល

ការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលត្រូវអនុវត្តផ្អែកតាមគោលការណ៍ដូចខាងក្រោម៖

ក- ទិន្នន័យបុគ្គលត្រូវធ្វើប្រព្រឹត្តកម្មដោយត្រូវអនុលោមតាមច្បាប់ យុត្តិធម៌ និងតម្លាភាព។

ខ- ទិន្នន័យបុគ្គលត្រូវប្រមូលសម្រាប់តែគោលបំណងជាក់លាក់ ច្បាស់លាស់ និងធម្មានុរូប និងមិនត្រូវធ្វើប្រព្រឹត្តកម្មបន្ថែមផ្សេងទៀតដែលមិនសមស្របនឹងគោលបំណងដើមនោះឡើយ លើកលែងតែការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលសម្រាប់បំណងរក្សាទុកក្នុងបណ្ណសារជាផលប្រយោជន៍សាធារណៈ ឬការស្រាវជ្រាវបែបវិទ្យាសាស្ត្រ ឬប្រវត្តិសាស្ត្រ ឬស្ថិតិ ដោយអនុលោមតាមគោលការណ៍ណែនាំរួមស្តីពីកិច្ចការពារទិន្នន័យបុគ្គល។

គ- ទិន្នន័យបុគ្គលត្រូវមានលក្ខណៈសមស្រប មានភាពពាក់ព័ន្ធ និងត្រឹមកម្រិតចាំបាច់សម្រាប់គោលបំណងនៃការធ្វើប្រព្រឹត្តកម្មតែប៉ុណ្ណោះ។

ឃ- ទិន្នន័យបុគ្គលដែលធ្វើប្រព្រឹត្តកម្មត្រូវមានភាពត្រឹមត្រូវ និងត្រូវធ្វើបច្ចុប្បន្នកម្មតាមការចាំបាច់។ ទិន្នន័យបុគ្គលដែលមិនត្រឹមត្រូវ ត្រូវលុបចេញ ឬកែតម្រូវដោយគ្មានការពន្យារពេលតាមមធ្យោបាយសមរម្យផ្អែកតាមគោលបំណងនៃការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គល។

ង- ទិន្នន័យបុគ្គលត្រូវរក្សាទុកក្នុងទម្រង់ដែលអាចកំណត់អត្តសញ្ញាណនៃប្រធានទិន្នន័យត្រឹមតែរយៈពេលចាំបាច់ សម្រាប់តែគោលបំណងនៃការធ្វើប្រព្រឹត្តកម្មទិន្នន័យតែប៉ុណ្ណោះ លើកលែងតែការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលសម្រាប់បំណងរក្សាទុកក្នុងបណ្ណសារជាផលប្រយោជន៍សាធារណៈ ឬការស្រាវជ្រាវបែបវិទ្យាសាស្ត្រ ឬប្រវត្តិសាស្ត្រ ឬស្ថិតិ ស្របតាមគោលការណ៍ណែនាំស្តីពីកិច្ចការពារទិន្នន័យបុគ្គលឬមានភាពចាំបាច់ដែលត្រូវអនុវត្តកាតព្វកិច្ចតាមច្បាប់ជាធរមាន។

ច- ទិន្នន័យបុគ្គលត្រូវធ្វើប្រព្រឹត្តកម្មក្នុងទម្រង់ដែលធានាសន្តិសុខនៃទិន្នន័យបុគ្គលតាមវិធានការបច្ចេកទេសនិងវិធានការគ្រប់គ្រងទិន្នន័យបុគ្គល ដូចមានចែងក្នុងមាត្រា៣៩ នៃច្បាប់នេះ។

បុគ្គលគ្រប់គ្រងទិន្នន័យត្រូវទទួលខុសត្រូវអនុវត្តនិងបង្ហាញពីអនុលោមភាពចំពោះគោលការណ៍នៃការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គល ដូចមានកំណត់ក្នុងមាត្រានេះ។

មាត្រា៧ ៖ មូលដ្ឋានគតិយុត្តនៃការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គល

ការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលត្រូវ ផ្អែកលើមូលដ្ឋានគតិយុត្តណាមួយ ដូចខាងក្រោម៖

ក- ការយល់ព្រមពីប្រធានទិន្នន័យ។

ខ- ភាពចាំបាច់នៃការអនុវត្តកិច្ចសន្យាដែលមានប្រធានទិន្នន័យជាភាគីនៃកិច្ចសន្យា ឬតាមសំណើរបស់ប្រធានទិន្នន័យមុនការបង្កើតកិច្ចសន្យា។

គ- ភាពចាំបាច់របស់បុគ្គលគ្រប់គ្រងទិន្នន័យដែលត្រូវអនុវត្តកាតព្វកិច្ចតាមច្បាប់។

ឃ- ភាពចាំបាច់សម្រាប់ការពារអាយុជីវិតរបស់ប្រធានទិន្នន័យ ឬរូបវន្តបុគ្គលផ្សេងទៀត។

ង- ភាពចាំបាច់សម្រាប់គោលបំណងនៃការបំពេញភារកិច្ចក្នុងផលប្រយោជន៍សាធារណៈ។

ច- ភាពចាំបាច់សម្រាប់គោលបំណងនៃផលប្រយោជន៍ធម្មានុរូបរបស់បុគ្គលគ្រប់គ្រងទិន្នន័យ ឬតតិយជន។

មាត្រា៨ ៖ ការយល់ព្រមពីប្រធានទិន្នន័យ

ការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលដែលផ្អែកលើចំណុច ក នៃមាត្រា៧ នៃច្បាប់នេះ ត្រូវមានការជូនដំណឹងអំពីគោលបំណងនៃការធ្វើប្រព្រឹត្តកម្ម និងត្រូវទទួលបានការយល់ព្រមច្បាស់លាស់ពីប្រធានទិន្នន័យចំពោះគោលបំណងនោះ។ បុគ្គលគ្រប់គ្រងទិន្នន័យត្រូវតែមានលទ្ធភាពក្នុងការបង្ហាញភស្តុតាងដែលអាចបញ្ជាក់អំពីការយល់ព្រមរបស់ប្រធានទិន្នន័យចំពោះការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គល ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

ការជូនដំណឹងទៅប្រធានទិន្នន័យត្រូវគោរពតាមលក្ខខណ្ឌ ដូចខាងក្រោម៖

ក- ត្រូវមានទម្រង់ងាយយល់ និងមានភាពច្បាស់លាស់។

ខ- ត្រូវធ្វើមុនការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គល។

គ- ត្រូវបញ្ជាក់អំពីគោលបំណងនៃការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលឱ្យបានជាក់លាក់ និងសមរម្យ និងត្រូវផ្តល់ព័ត៌មានពាក់ព័ន្ធនឹងគោលបំណងនោះ។

ឃ- ត្រូវប្រាប់អំពីសិទ្ធិនៃការដកការយល់ព្រមនិងសិទ្ធិផ្សេងទៀតរបស់ប្រធានទិន្នន័យដែលកំណត់ដោយច្បាប់នេះ។

ង- ត្រូវផ្តល់ព័ត៌មានទៅប្រធានទិន្នន័យអំពីមន្ត្រីកិច្ចការពារទិន្នន័យបុគ្គលរបស់បុគ្គលគ្រប់គ្រងទិន្នន័យ ឬអ្នកតំណាងផ្សេងទៀតប្រសិនបើមាន ដើម្បីឱ្យប្រធានទិន្នន័យអាចសាកសួរព័ត៌មាន ឬស្នើសុំការពន្យល់។

ក្នុងករណីការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលរបស់ប្រធានទិន្នន័យដែលមានអាយុក្រោម ១៦(ដប់ប្រាំមួយ) ឆ្នាំ ត្រូវមានការយល់ព្រមរបស់ឪពុកម្តាយ ឬអាណាព្យាបាលរបស់ប្រធានទិន្នន័យនោះ។ ក្នុងករណីនេះ បុគ្គលគ្រប់គ្រងទិន្នន័យត្រូវពិនិត្យនិងផ្ទៀងផ្ទាត់ការយល់ព្រមរបស់ឪពុកម្តាយឬអាណាព្យាបាលនោះតាមរយៈបច្ចេកវិទ្យាដែលមាន ឬតាមមធ្យោបាយផ្សេងទៀតដែលអាចធ្វើទៅបាន។

ប្រធានទិន្នន័យមានសិទ្ធិដកការយល់ព្រមចំពោះការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលសម្រាប់គោលបំណងជាក់លាក់ណាមួយនៅពេលណាក៏បាន តាមរយៈការជូនដំណឹងទៅបុគ្គលគ្រប់គ្រងទិន្នន័យ។ បុគ្គលគ្រប់គ្រងទិន្នន័យត្រូវបង្កលក្ខណៈងាយស្រួល ចំពោះការដកការយល់ព្រម។ នៅពេលទទួលបានការជូនដំណឹងអំពីការដកការយល់ព្រមនោះ បុគ្គលគ្រប់គ្រងទិន្នន័យត្រូវជូនដំណឹងទៅប្រធានទិន្នន័យអំពីផលវិបាកនៃការដកការយល់ព្រម និងត្រូវបញ្ឈប់ការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលនោះភ្លាម។ ការដកការយល់ព្រមមិនត្រូវមានអានុភាពប្រតិសកម្មដល់ការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលដែលផ្អែកលើការយល់ព្រមកន្លងមកនោះទេ។

មាត្រា៩ .. តាពចាំបាច់នៃការអនុវត្តកិច្ចសន្យា ឬការផ្តួចផ្តើមបង្កើតកិច្ចសន្យា

ការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលផ្អែកលើចំណុច ខ នៃមាត្រា៧ នៃច្បាប់នេះ ត្រូវមានភាពចាំបាច់សម្រាប់ការអនុវត្តកិច្ចសន្យាដែលមានប្រធានទិន្នន័យជាភាគីនៃកិច្ចសន្យា ឬតាមសំណើរបស់ប្រធានទិន្នន័យមុនការបង្កើតកិច្ចសន្យា។ ភាពចាំបាច់នេះត្រូវអនុវត្តយ៉ាងតឹងរឹងបំផុត ដោយគិតគូរអំពីប្រភេទនិងគោលបំណងនៃកិច្ចសន្យា និងត្រូវគោរពតាមគោលការណ៍នៃការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលដូចមានចែងក្នុងមាត្រា៦ នៃច្បាប់នេះ។

ការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលផ្អែកលើការអនុវត្តកិច្ចសន្យាត្រូវបញ្ឈប់ស្របតាមលក្ខខណ្ឌនៃកិច្ចសន្យាដែលគូភាគីបានព្រមព្រៀង។

មាត្រា១០ .. តាពចាំបាច់សម្រាប់ការអនុវត្តភាតព្វកិច្ចតាមច្បាប់

ការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលផ្អែកលើចំណុច គ នៃមាត្រា៧ នៃច្បាប់នេះ ត្រូវមានភាពចំបាច់ដើម្បីអនុវត្តភាតព្វកិច្ចដែលកំណត់ដោយច្បាប់។ ក្នុងករណីនេះ ការបង្ហាញអំពីបទប្បញ្ញត្តិដែលជាការអនុវត្តភាតព្វកិច្ចតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានគឺជាបន្ទុករបស់បុគ្គលគ្រប់គ្រងទិន្នន័យ។

មាត្រា១១ .. តាពចាំបាច់សម្រាប់ការពារអាយុជីវិត

ការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលផ្អែកលើចំណុច ឃ នៃមាត្រា៧ នៃច្បាប់នេះ ត្រូវមានភាពចាំបាច់សម្រាប់កិច្ចការពារអាយុជីវិតរបស់ប្រធានទិន្នន័យ ឬបុគ្គលពាក់ព័ន្ធផ្សេងទៀតដែលនឹងទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ។ ក្នុងករណីនេះ បុគ្គលគ្រប់គ្រងទិន្នន័យត្រូវបង្ហាញថា ខ្លួនមានហេតុផលសមរម្យដែលអាចជឿជាក់បានថា មានការគំរាមកំហែងដល់សុខភាព ឬសុវត្ថិភាពរបស់ប្រធានទិន្នន័យ ឬបុគ្គលពាក់ព័ន្ធផ្សេងទៀតដែលនឹងត្រូវទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ។

មាត្រា១២ .. តាពចាំបាច់សម្រាប់ការបំពេញតារកិច្ចក្នុងផលប្រយោជន៍សាធារណៈ

ការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលផ្អែកលើចំណុច ង នៃមាត្រា៧ នៃច្បាប់នេះ ត្រូវគោរពតាមលក្ខខណ្ឌណាមួយដូចខាងក្រោម៖

ក- ការអនុវត្តសិទ្ធិតាមច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តដែលអនុញ្ញាតឱ្យបុគ្គលគ្រប់គ្រងទិន្នន័យបំពេញភារកិច្ចក្នុងផលប្រយោជន៍ជាតិ ឬផលប្រយោជន៍សាធារណៈ។

ខ- ការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលដែលអាចរកបានជាសាធារណៈ។

គ- ការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលសម្រាប់តែគោលបំណងសិល្បៈអក្សរសាស្ត្រ បណ្ណសារឬប្រវត្តិសាស្ត្រ។

ឃ- ការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលដោយអង្គភាពសារព័ត៌មានសម្រាប់តែគោលបំណងផ្សព្វផ្សាយព័ត៌មានប៉ុណ្ណោះ។

មាត្រា១៣ .. តាពចាំបាច់សម្រាប់គោលបំណងនៃផលប្រយោជន៍ធម្មានុរូប

ការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលផ្អែកលើចំណុច ច នៃមាត្រា៧ នៃច្បាប់នេះ ត្រូវធ្វើការវាយតម្លៃផលប្រយោជន៍ធម្មានុរូបមុនពេលធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គល។

ការវាយតម្លៃផលប្រយោជន៍ធម្មានុរូបត្រូវបង្ហាញថា ផលប្រយោជន៍ធម្មានុរូបរបស់បុគ្គលគ្រប់គ្រងទិន្នន័យឬតតិយជនមានតម្លៃលើសសិទ្ធិមូលដ្ឋាន និងសេរីភាពរបស់ប្រធានទិន្នន័យ។ បុគ្គលគ្រប់គ្រងទិន្នន័យត្រូវយកចិត្តទុកដាក់ជាពិសេសក្នុងការការពារឧត្តមប្រយោជន៍របស់ប្រធានទិន្នន័យដែលមានអាយុក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ។

មាត្រា១៤ ៖ កិច្ចការពារទិន្នន័យបុគ្គលវេទយិត

ការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលវេទយិត ត្រូវបានហាមឃាត់។

កថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវបានអនុវត្តទេក្នុងករណីដែលបុគ្គលគ្រប់គ្រងទិន្នន័យធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលវេទយិតដោយគោរពតាមមូលដ្ឋានគតិយុត្តដូចមានចែងមាត្រា៧ នៃច្បាប់នេះ និងបំពេញតាមលក្ខខណ្ឌបន្ថែមណាមួយ ដូចខាងក្រោម៖

ក- ការយល់ព្រមច្បាស់លាស់ពីប្រធានទិន្នន័យ។

ខ- ភាពចាំបាច់សម្រាប់អនុវត្តកាតព្វកិច្ច និងសិទ្ធិជាក់លាក់របស់បុគ្គលគ្រប់គ្រងទិន្នន័យ ឬប្រធានទិន្នន័យនៅក្នុងវិស័យការងារ សន្តិសុខសង្គម និងគាំពារសង្គម ដែលកំណត់ដោយច្បាប់។

គ- ភាពចាំបាច់សម្រាប់ការពារអាយុជីវិតរបស់ប្រធានទិន្នន័យ ឬបុគ្គលពាក់ព័ន្ធផ្សេងទៀតក្នុងករណីដែលប្រធានទិន្នន័យមិនអាចផ្តល់ការយល់ព្រមដោយផ្ទាល់ ឬខ្វះសមត្ថភាពតាមផ្លូវច្បាប់ក្នុងការផ្តល់ការយល់ព្រម។

ឃ- ការធ្វើសកម្មភាពស្របច្បាប់ដោយនីតិបុគ្គលមិនយកចំណេញដែលមានគោលបំណងនយោបាយ ទស្សនវិជ្ជា សាសនា ឬសហជីព ដែលពាក់ព័ន្ធនឹងសមាជិក ឬអតីតសមាជិករបស់ខ្លួន ឬរបៀបបុគ្គលដែលមានទំនាក់ទំនងជាប្រចាំជាមួយនឹងនីតិបុគ្គលមិនយកចំណេញ។ ក្នុងករណីនេះ នីតិបុគ្គលមិនយកចំណេញត្រូវមានប្រព័ន្ធការពារទិន្នន័យសមស្របសម្រាប់ការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលនេះ ហើយមិនត្រូវលាតត្រដាងទិន្នន័យបុគ្គលនេះទៅខាងក្រៅដោយគ្មានការយល់ព្រមពីប្រធានទិន្នន័យឡើយ។

ង- ទិន្នន័យបុគ្គលដែលលាតត្រដាងជាសាធារណៈ ដោយប្រធានទិន្នន័យ។

ច- ភាពចាំបាច់សម្រាប់ការបង្កើតសិទ្ធិតាមផ្លូវច្បាប់ ការអនុវត្តសិទ្ធិតាមផ្លូវច្បាប់ ឬការការពារសិទ្ធិតាមផ្លូវច្បាប់ ឬនៅពេលដែលតុលាការកំពុងអនុវត្តភារកិច្ចក្នុងសមត្ថកិច្ចតុលាការរបស់ខ្លួន។

ឆ- ភាពចាំបាច់ព្រោះហេតុផលនៃផលប្រយោជន៍សាធារណៈដ៏មានសារសំខាន់ ដែលកំណត់ដោយច្បាប់។ ក្នុងករណីនេះ ការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលត្រូវមានសមាមាត្រជាមួយនឹងគោលបំណងនៃការធ្វើប្រព្រឹត្តកម្ម គោរពសារសំខាន់នៃសិទ្ធិ និងត្រូវមានវិធានការជាក់លាក់ និងសមរម្យដើម្បីការពារសិទ្ធិ និងសេរីភាពមូលដ្ឋានរបស់ប្រធានទិន្នន័យ។

ជ- ភាពចាំបាច់សម្រាប់គោលបំណងវេជ្ជសាស្ត្រ និងសុខភាពសាធារណៈដែលកំណត់ដោយច្បាប់ និងត្រូវមានវិធានការជាក់លាក់ និងសមរម្យដើម្បីការពារសិទ្ធិនិងសេរីភាពមូលដ្ឋានរបស់ប្រធានទិន្នន័យ។

ឈ-ភាពចាំបាច់សម្រាប់គោលបំណងរក្សាទុកក្នុងបណ្ណសារជាផលប្រយោជន៍សាធារណៈ ឬការស្រាវជ្រាវបែបវិទ្យាសាស្ត្រ ឬប្រវត្តិសាស្ត្រ ឬស្ថិតិដែលកំណត់ដោយច្បាប់។ ក្នុងករណីនេះ ការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលត្រូវមានសមាមាត្រជាមួយនឹងគោលបំណងនៃការធ្វើប្រព្រឹត្តកម្ម គោរពសារៈសំខាន់នៃសិទ្ធិ និងត្រូវមានវិធានការជាក់លាក់ និងសមរម្យដើម្បីការពារសិទ្ធិមូលដ្ឋាន និងសេរីភាពរបស់ប្រធានទិន្នន័យ។

ជំពូកទី៤
បុគ្គលគ្រប់គ្រងទិន្នន័យ និងបុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ

មាត្រា១៥ .. វិធានការការពារទិន្នន័យបុគ្គលផ្អែកតាមនិម្មាបនកម្មបច្ចេកទេស និងវិធានការពារទិន្នន័យបុគ្គលផ្អែកតាមបុរេជម្រើស

បុគ្គលគ្រប់គ្រងទិន្នន័យត្រូវអនុវត្តវិធាការនិម្មាបនកម្មបច្ចេកទេសនៃកិច្ចការពារទិន្នន័យបុគ្គល ដោយបញ្ចូលវិធានការសុវត្ថិភាពដែលចាំបាច់សម្រាប់តែគោលបំណងជាក់លាក់ ក្នុងការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គល។ វិធានការនេះត្រូវយកមកអនុវត្តទាំងនៅពេលចាប់ផ្តើមកំណត់មធ្យោបាយសម្រាប់ការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលនិងនៅពេលចាប់ផ្តើមធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គល។

បុគ្គលគ្រប់គ្រងទិន្នន័យត្រូវអនុវត្តវិធានការបុរេជម្រើសនៃកិច្ចការពារទិន្នន័យបុគ្គលក្នុងការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គល ដោយធានាថាមានតែទិន្នន័យបុគ្គលដែលចាំបាច់សម្រាប់គោលបំណងជាក់លាក់ណាមួយប៉ុណ្ណោះត្រូវបានធ្វើប្រព្រឹត្តកម្ម។ វិធានការនេះត្រូវយកមកអនុវត្តដោយកំណត់អំពីចំនួនទិន្នន័យបុគ្គលដែលត្រូវប្រមូល ទំហំនៃការធ្វើប្រព្រឹត្តកម្ម រយៈពេលនៃការរក្សាទុក និងភាពងាយស្រួលក្នុងការអាក់សេស ។

មាត្រា១៦ .. អ្នកតំណាងរបស់បុគ្គលគ្រប់គ្រងទិន្នន័យឬបុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ

បុគ្គលគ្រប់គ្រងទិន្នន័យនិងបុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យដែលមានទីតាំងនៅក្រៅព្រះរាជាណាចក្រកម្ពុជាដែលពាក់ព័ន្ធនឹងការផ្តត់ផ្តង់ទំនិញឬសេវាឬការតាមដានសកម្មភាព ចំពោះប្រធានទិន្នន័យដែលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវចាត់តាំងអ្នកតំណាង និងផ្តល់ឈ្មោះនិងព័ត៌មានទំនាក់ទំនងមកក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការចាត់តាំងអ្នកតំណាង និងផ្តល់ឈ្មោះនិងព័ត៌មានទំនាក់ទំនងមកក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវកំណត់ក្នុងគោលការណ៍ណែនាំរួមស្តីពីកិច្ចការពារទិន្នន័យបុគ្គល។

មាត្រា១៧ .. កិច្ចសន្យារវាងបុគ្គលគ្រប់គ្រងទិន្នន័យនិងបុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ

បុគ្គលគ្រប់គ្រងទិន្នន័យនិងបុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យត្រូវមានកិច្ចសន្យាជាលាយលក្ខណ៍អក្សរដែលកំណត់អំពីកម្មវត្ថុ រយៈពេលនៃការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គល លក្ខណៈនិងគោលបំណងនៃការធ្វើប្រព្រឹត្តកម្មទិន្នន័យ ប្រភេទនៃទិន្នន័យបុគ្គល ចំណាត់ថ្នាក់នៃប្រធានទិន្នន័យ នីតិវិធីនៃការជូនដំណឹងអំពីការបែកធ្លាយទិន្នន័យបុគ្គល ព្រមទាំងកាតព្វកិច្ច និងសិទ្ធិរបស់បុគ្គលគ្រប់គ្រងទិន្នន័យ។

បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យមិនត្រូវធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលមុនការចុះកិច្ចសន្យាស្តីពីការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលជាមួយបុគ្គលគ្រប់គ្រងទិន្នន័យឡើយ។ បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យត្រូវធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលដោយអនុលោមតាមកិច្ចសន្យា និងបទប្បញ្ញត្តិនៃច្បាប់នេះ ហើយត្រូវលុបចោល និង/ឬប្រគល់ទិន្នន័យបុគ្គលទៅឱ្យបុគ្គលគ្រប់គ្រងទិន្នន័យ បន្ទាប់ពីបញ្ចប់ការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គល។

លក្ខខណ្ឌលម្អិត នៃកិច្ចសន្យារវាងបុគ្គលគ្រប់គ្រងទិន្នន័យនិងបុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលត្រូវកំណត់ក្នុងគោលការណ៍ណែនាំរួមស្តីពីកិច្ចការពារទិន្នន័យបុគ្គល។

មាត្រា១៨ .. ការរក្សាកំណត់ត្រាទិន្នន័យបុគ្គល

បុគ្គលគ្រប់គ្រងទិន្នន័យ និងបុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យត្រូវរៀបចំ និងរក្សាទុកកំណត់ត្រានូវរាល់សកម្មភាពនៃការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលដែលស្ថិតនៅក្រោមការទទួលខុសត្រូវ ឬការគ្រប់គ្រងរបស់ខ្លួន។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការរៀបចំនិងការរក្សាទុកកំណត់ត្រានូវរាល់សកម្មភាពនៃការធ្វើប្រព្រឹត្តកម្ម ត្រូវកំណត់ក្នុងគោលការណ៍ណែនាំរួមស្តីពីកិច្ចការពារទិន្នន័យបុគ្គល។

មាត្រា១៩ ៖ ការវាយតម្លៃផលប៉ះពាល់ទិន្នន័យបុគ្គល

ក្នុងករណីដែលបុគ្គលគ្រប់គ្រងទិន្នន័យយល់ឃើញថា ការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលមានហានិភ័យខ្ពស់ប៉ះពាល់ដល់សិទ្ធិនិងសេរីភាពរបស់ប្រធានទិន្នន័យនិង/ឬរូបវន្តបុគ្គលផ្សេងទៀត បុគ្គលគ្រប់គ្រងទិន្នន័យត្រូវធ្វើការវាយតម្លៃផលប៉ះពាល់ទិន្នន័យបុគ្គល ដោយប្លឹងថ្លែងអំពីប្រភេទ វិសាលភាព បរិបទ និងគោលបំណងនៃការធ្វើប្រព្រឹត្តកម្មទិន្នន័យនោះ ហើយត្រូវផ្តល់របាយការណ៍វាយតម្លៃផលប៉ះពាល់ទិន្នន័យបុគ្គលមកក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

របាយការណ៍វាយតម្លៃផលប៉ះពាល់ទិន្នន័យបុគ្គលត្រូវមាន៖

ក- ការពិពណ៌នាអំពីគោលបំណងនិងមធ្យោបាយនៃដំណើរការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គល។

ខ- ការវាយតម្លៃហានិភ័យដែលប៉ះពាល់ដល់សិទ្ធិនិងសេរីភាពរបស់ប្រធានទិន្នន័យនិង/ឬរូបវន្តបុគ្គលផ្សេងទៀត។

គ- វិធានការដែលឆ្លើយតបទៅនឹងហានិភ័យ។

ឃ- វិធានការសន្តិសុខ និងយន្តការផ្សេងទៀត ដើម្បីធានាកិច្ចការពារទិន្នន័យបុគ្គល។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការវាយតម្លៃផលប៉ះពាល់ទិន្នន័យបុគ្គល ត្រូវកំណត់ក្នុងគោលការណ៍ណែនាំរួមស្តីពីកិច្ចការពារទិន្នន័យបុគ្គល។

មាត្រា២០ ៖ សន្តិសុខនៃការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គល

បុគ្គលគ្រប់គ្រងទិន្នន័យ និងបុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ ត្រូវអនុវត្តវិធានការបច្ចេកទេស និងវិធានការគ្រប់គ្រងដើម្បីធានាសុវត្ថិភាពនៃការធ្វើប្រព្រឹត្តិកម្មទិន្នន័យបុគ្គលនិងបង្ការទប់ស្កាត់សកម្មភាពដូចខាងក្រោម៖

ក- ហានិភ័យនៃការអាក់សេស ការប្រមូល ការប្រើប្រាស់ ការលាតត្រដាង ការចម្លង ការកែប្រែ ឬការលុបចោល ដោយគ្មានការអនុញ្ញាត ព្រមទាំងហានិភ័យប្រហាក់ប្រហែលផ្សេងទៀត។

ខ- ការបាត់បង់មធ្យោបាយឬឧបករណ៍ដែលរក្សាទុកទិន្នន័យបុគ្គល។

ចំពោះការរៀបចំវិធានការបច្ចេកទេស និងវិធានការគ្រប់គ្រង ដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ បុគ្គលគ្រប់គ្រងទិន្នន័យ និងបុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ ត្រូវប្លឹងថ្លែងអំពីលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

ក- ហានិភ័យនៃការធ្វើប្រព្រឹត្តកម្មទិន្នន័យដែលអាចប៉ះពាល់ដល់សិទ្ធិ និងសេរីភាពរបស់ប្រធានទិន្នន័យ។

ខ- ប្រភេទ វិសាលភាព បរិបទ និងគោលបំណងនៃការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គល។

គ- ស្ថានភាពចុងក្រោយនៃបច្ចេកវិទ្យា។

ឃ- ការចំណាយក្នុងការអនុវត្តវិធានការ ដោយពិចារណាអំពីស្ថានភាពនិងហានិភ័យនៃការធ្វើប្រព្រឹត្តកម្មរបស់ខ្លួន។

បន្ទាប់ពីប្លឹងថ្លែងលើលក្ខខណ្ឌ ដូចមានចែងក្នុងកថាខណ្ឌទី២ ខាងលើនេះ បុគ្គលគ្រប់គ្រងទិន្នន័យ និងបុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យត្រូវដាក់ចេញនូវវិធានការសមរម្យមួយចំនួនដូចខាងក្រោម៖

ក- ការធ្វើរហស្សនាមកម្ម និងការធ្វើកូដនីយកម្មនៃទិន្នន័យបុគ្គល តាមករណីចាំបាច់។

ខ- ការធានាភាពសម្ងាត់ បូរណភាព និងលទ្ធភាពនៃការប្រើប្រាស់ និងភាពធន់នៃប្រព័ន្ធធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គល និងសេវា។

គ- ការធានាឱ្យមានការប្រើប្រាស់ និងការអាក់សេសឡើងវិញទៅកាន់ទិន្នន័យបុគ្គលឱ្យទាន់ពេលវេលាក្នុងករណីមានឧប្បត្តិហេតុកើតឡើង។

ឃ- ការធ្វើតេស្ត ការវាស់ស្ទង់ និងការវាយតម្លៃជាប្រចាំអំពីប្រសិទ្ធភាពនៃវិធានការបច្ចេកទេស និងវិធានការគ្រប់គ្រងដើម្បីធានាសុវត្ថិភាពនៃការធ្វើប្រព្រឹត្តិកម្មទិន្នន័យបុគ្គល។

មាត្រា២១ .. ការជូនដំណឹងទៅក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍អំពីការបែកធ្លាយទិន្នន័យបុគ្គល

ក្នុងករណីដែលមានការបែកធ្លាយទិន្នន័យបុគ្គល ហើយការបែកធ្លាយនោះអាចមានហានិភ័យប៉ះពាល់ដល់ប្រធានទិន្នន័យនិង/ឬរូបវន្តបុគ្គលផ្សេងទៀត បុគ្គលគ្រប់គ្រងទិន្នន័យត្រូវជូនដំណឹងមកក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ភ្លាម ដែលមិនត្រូវលើសពី ៧២ (ចិតសិបពីរ) ម៉ោង គិតចាប់ពីពេលដែលបានដឹងអំពីការបែកធ្លាយទិន្នន័យបុគ្គលនោះ។ ក្នុងករណីបុគ្គលគ្រប់គ្រងទិន្នន័យមិនអាចជូនដំណឹងមកក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងទេ បុគ្គលគ្រប់គ្រងទិន្នន័យត្រូវបង្ហាញហេតុផលសមស្របដែលបណ្តាលឱ្យមានការយឺតយ៉ាវនោះ។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការជូនដំណឹងអំពីការបែកធ្លាយទិន្នន័យបុគ្គលទៅក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវកំណត់ក្នុងគោលការណ៍ណែនាំរួមស្តីពីកិច្ចការពារទិន្នន័យបុគ្គល។

មាត្រា២២ .. ការជូនដំណឹងទៅប្រធានទិន្នន័យអំពីការបែកធ្លាយទិន្នន័យបុគ្គល

ក្នុងករណីដែលមានការបែកធ្លាយទិន្នន័យបុគ្គល ហើយការបែកធ្លាយនោះអាចមានហានិភ័យខ្ពស់ប៉ះពាល់ដល់សិទ្ធិនិងសេរីភាពរបស់ប្រធានទិន្នន័យ បុគ្គលគ្រប់គ្រងទិន្នន័យត្រូវជូនដំណឹងមកប្រធានទិន្នន័យភ្លាម គិតចាប់ពីពេលដែលបានដឹងអំពីការបែកធ្លាយទិន្នន័យបុគ្គលនោះ។

បទប្បញ្ញត្តិក្នុងកថាខណ្ឌទី១ ខាងលើនេះ មិនត្រូវអនុវត្តទេ ក្នុងលក្ខខណ្ឌណាមួយដូចខាងក្រោម៖

ក- បុគ្គលគ្រប់គ្រងទិន្នន័យបាននិងកំពុងអនុវត្តវិធានការបច្ចេកទេស និងវិធានការគ្រប់គ្រងដើម្បីធានាសុវត្ថិភាពនៃទិន្នន័យបុគ្គលដែលរងផលប៉ះពាល់ពីការបែកធ្លាយទិន្នន័យបុគ្គល មានជាអាទិ៍ ការធ្វើកូដនីយកម្ម ឬការលុបអត្តសញ្ញាណទិន្នន័យជាដើម។

ខ- បុគ្គលគ្រប់គ្រងទិន្នន័យបានចាត់វិធានការជាបន្តបន្ទាប់ ដែលធានាថាហានិភ័យខ្ពស់ដែលប៉ះពាល់ដល់សិទ្ធិនិងសេរីភាពរបស់ប្រធានទិន្នន័យត្រូវបានដោះស្រាយ។

គ- ការជូនដំណឹងអំពីការបែកធ្លាយទិន្នន័យបុគ្គលទៅប្រធានទិន្នន័យម្នាក់ៗបង្កើតជាបន្ទុកឬចំណាយដល់បុគ្គលគ្រប់គ្រងទិន្នន័យលើសលុបមិនសមហេតុសមផល ឬមិនអាចធ្វើទៅបានដោយប្រការណាមួយ។ ក្នុងករណីនេះ បុគ្គលគ្រប់គ្រងទិន្នន័យអាចជូនដំណឹងជាសាធារណៈ ឬប្រើប្រាស់មធ្យោបាយប្រហាក់ប្រហែលដើម្បីជូនដំណឹងទៅប្រធានទិន្នន័យឱ្យមានប្រសិទ្ធភាពដូចគ្នានឹងការជូនដំណឹងទៅប្រធានទិន្នន័យម្នាក់ៗ។

ប្រសិនបើបុគ្គលគ្រប់គ្រងទិន្នន័យមិនបានជូនដំណឹងទៅប្រធានទិន្នន័យអំពីការបែកធ្លាយទិន្នន័យបុគ្គលដោយហេតុផលថាមិនមានហានិភ័យខ្ពស់ដូចមានចែងក្នុងកថាខណ្ឌទី១ ឬលក្ខខណ្ឌណាមួយ ដូចមានចែងក្នុងកថាខណ្ឌទី២ ខាងលើនេះ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍អាចតម្រូវឱ្យបុគ្គលគ្រប់គ្រងទិន្នន័យជូនដំណឹងទៅប្រធានទិន្នន័យ ក្នុងករណីដែលខ្លួនយល់ឃើញថា ការបែកធ្លាយទិន្នន័យបុគ្គលនោះមានហានិភ័យខ្ពស់ប៉ះពាល់ដល់សិទ្ធិនិងសេរីភាពរបស់ប្រធានទិន្នន័យ។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការជូនដំណឹងអំពីការបែកធ្លាយទិន្នន័យបុគ្គលទៅប្រធានទិន្នន័យ ត្រូវកំណត់ក្នុងគោលការណ៍ណែនាំរួមស្តីពីកិច្ចការពារទិន្នន័យបុគ្គល។

មាត្រា២៣ ៖ ការផ្ទេរទិន្នន័យបុគ្គលទៅក្រៅព្រះរាជាណាចក្រកម្ពុជា

បុគ្គលគ្រប់គ្រងទិន្នន័យមិនអាចផ្ទេរទិន្នន័យបុគ្គលទៅក្រៅព្រះរាជាណាចក្រកម្ពុជាបានទេ លើកលែងតែមានការបំពេញលក្ខខណ្ឌណាមួយ ដូចខាងក្រោម៖

ក- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ផ្តល់ការអនុញ្ញាតឱ្យផ្ទេរទិន្នន័យបុគ្គល។

ខ- បុគ្គលគ្រប់គ្រងទិន្នន័យវាយតម្លៃថា មានវិធានការការពារសមរម្យសម្រាប់ការពារទិន្នន័យបុគ្គលដែលត្រូវផ្ទេរទៅក្រៅព្រះរាជាណាចក្រកម្ពុជា។

គ- ការផ្ទេរទិន្នន័យបុគ្គលទៅក្រៅព្រះរាជាណាចក្រកម្ពុជា ផ្អែកលើកាល:ទេស:ពិសេសណាមួយមានជាអាទិ៍៖

១- ការយល់ព្រមជាលាយលក្ខណ៍អក្សរពីប្រធានទិន្នន័យ។

២- ភាពចាំបាច់សម្រាប់ការអនុវត្តកិច្ចសន្យារវាងប្រធានទិន្នន័យ និងបុគ្គលគ្រប់គ្រងទិន្នន័យ។

៣- ការពារផលប្រយោជន៍សាធារណៈ។

៤- ការការពារអាយុជីវិតរបស់ប្រធានទិន្នន័យ ឬបុគ្គលពាក់ព័ន្ធផ្សេងទៀត។

៥- ការការពារផលប្រយោជន៍ធម្មានុរូបរបស់ប្រធានទិន្នន័យ។

៦- ការបង្កើតសិទ្ធិតាមផ្លូវច្បាប់ការអនុវត្តសិទ្ធិតាមផ្លូវច្បាប់ ឬការការពារសិទ្ធិតាមផ្លូវច្បាប់ ឬនៅពេលដែលតុលាការកំពុងអនុវត្តភារកិច្ចក្នុងសមត្ថកិច្ចតុលាការរបស់ខ្លួន។

បុគ្គលគ្រប់គ្រងទិន្នន័យត្រូវមានលទ្ធភាពផ្តល់ភស្តុតាងមកក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ក្នុងករណីលក្ខខណ្ឌ (ខ) និង (គ) នៃកថាខណ្ឌទី១ ខាងលើនេះ។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្ទេរទិន្នន័យបុគ្គលទៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់ក្នុងគោលការណ៍ណែនាំរួមស្តីពីកិច្ចការពារទិន្នន័យបុគ្គល។

ជំពូកទី៥
មន្ត្រីកិច្ចការពារទិន្នន័យបុគ្គល

មាត្រា២៤ ៖ លក្ខខណ្ឌតម្រូវឱ្យមានមន្ត្រីកិច្ចការពារទិន្នន័យបុគ្គល

បុគ្គលគ្រប់គ្រងទិន្នន័យនិងបុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យត្រូវជ្រើសរើសមន្ត្រីកិច្ចការពារទិន្នន័យបុគ្គលដែលមានគុណវុឌ្ឍិក្នុងការប្រកបវិជ្ជាជីវៈកិច្ចការពារទិន្នន័យបុគ្គល។

បុគ្គលគ្រប់គ្រងទិន្នន័យនិងបុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យត្រូវជូនដំណឹងអំពីឈ្មោះនិងព័ត៌មានរបស់មន្ត្រីកិច្ចការពារទិន្នន័យបុគ្គលមកក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្នុងរយៈពេល ៣០(សាមសិប) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីថ្ងៃជ្រើសរើសបានមន្ត្រីកិច្ចការពារទិន្នន័យបុគ្គល។

កថាខណ្ឌទី២ ខាងលើនេះ ក៏ត្រូវអនុវត្តផងដែរក្នុងករណីមានការផ្លាស់ប្តូរមន្ត្រីកិច្ចការពារទិន្នន័យបុគ្គល។ ការជូនដំណឹងត្រូវធ្វើឡើងក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីថ្ងៃនៃការផ្លាស់ប្តូរ។

លក្ខណៈវិនិច្ឆ័យនៃការកំណត់ប្រភេទបុគ្គលគ្រប់គ្រងទិន្នន័យនិងបុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យដែលតម្រូវឱ្យមានមន្ត្រីកិច្ចការពារទិន្នន័យបុគ្គល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

មាត្រា២៥ .. តួនាទីនិងគុណវុឌ្ឍិនៃមន្ត្រីកិច្ចការពារទិន្នន័យបុគ្គល

មន្ត្រីកិច្ចការពារទិន្នន័យបុគ្គលមានតួនាទី ត្រួតពិនិត្យអនុលោមភាពនៃការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលដែលកំណត់ដោយច្បាប់នេះ។

រូបវន្តបុគ្គលទាំងឡាយដែលប្រកបវិជ្ជាជីវៈជាមន្ត្រីកិច្ចការពារទិន្នន័យបុគ្គល ត្រូវមានគុណវុឌ្ឍិគ្រប់គ្រាន់ក្នុងការប្រកបវិជ្ជាជីវៈជាមន្ត្រីកិច្ចការពារទិន្នន័យបុគ្គល និងមានវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈកិច្ចការពារទិន្នន័យបុគ្គល។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការទទួលបានវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈកិច្ចការពារទិន្នន័យបុគ្គល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

ជំពូកទី៦
សិទ្ធិរបស់ប្រធានទិន្នន័យ

មាត្រា២៦ .. វិធានទូទៅ

ដើម្បីធានាការអនុវត្តសិទ្ធិរបស់ប្រធានទិន្នន័យដូចមានចែងក្នុងជំពូកនេះ បុគ្គលគ្រប់គ្រងទិន្នន័យត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម៖

ក- ផ្តល់ព័ត៌មានទៅប្រធានទិន្នន័យក្នុងទម្រង់ងាយយល់ និងមានភាពច្បាស់លាស់។

ខ- សម្រួលដល់ការអនុវត្តសិទ្ធិរបស់ប្រធានទិន្នន័យ និងមិនត្រូវបដិសេធសំណើរបស់ប្រធានទិន្នន័យឡើយលើកលែងតែបុគ្គលគ្រប់គ្រងទិន្នន័យមិនអាចកំណត់អត្តសញ្ញាណរបស់ប្រធានទិន្នន័យបាន។

គ- ផ្តល់ព័ត៌មានអំពីសកម្មភាពរបស់ខ្លួនដែលត្រូវធ្វើពាក់ព័ន្ធនឹងសិទ្ធិរបស់ប្រធានទិន្នន័យដោយមិនមានការពន្យាពេល និង ក្នុងរយៈពេល ១ (មួយ) ខែ បន្ទាប់ពីថ្ងៃទទួលបានសំណើពីប្រធានទិន្នន័យ។ រយៈពេលនេះអាចត្រូវពន្យារបានបន្ថែមត្រឹម ២(ពីរ) ខែ ក្នុងករណីមានភាពចាំបាច់ដោយហេតុថាមានចំនួនសំណើច្រើន ហើយសំណើទាំងនោះមានភាពស្មុគស្មាញ។ ក្នុងករណីនេះ បុគ្គលគ្រប់គ្រងទិន្នន័យ ត្រូវជូនដំណឹងអំពីការស្នើសុំពន្យារពេលទៅប្រធានទិន្នន័យក្នុងរយៈពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃទទួលបានសំណើ ដោយមានបញ្ជាក់ហេតុផលនៃការស្នើសុំពន្យារពេលនោះ។

ឃ- ផ្តល់ព័ត៌មានទៅប្រធានទិន្នន័យដោយឥតគិតថ្លៃ។ ក្នុងករណីដែលប្រធានទិន្នន័យបានធ្វើការស្នើសុំលើសពី ២ (ពីរ) ដងក្នុងមួយត្រីមាស បុគ្គលគ្រប់គ្រងទិន្នន័យអាចគិតកម្រៃសមរម្យសម្រាប់ចំណាយរដ្ឋបាលដែលពាក់ព័ន្ធនឹងការផ្តល់ព័ត៌មាននោះ។

មាត្រា២៧ .. សិទ្ធិទទួលបានព័ត៌មាន

នៅមុនពេលធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលគ្រប់គ្រងទិន្នន័យត្រូវផ្តល់ព័ត៌មានទៅប្រធានទិន្នន័យដូចខាងក្រោម៖

ក- អត្តសញ្ញាណ និងព័ត៌មានទំនាក់ទំនងរបស់បុគ្គលគ្រប់គ្រងទិន្នន័យ។

ខ- មូលដ្ឋានគតិយុត្ត និងគោលបំណងនៃការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គល។

គ- ប្រភេទនៃទិន្នន័យបុគ្គលដែលពាក់ព័ន្ធនឹងប្រធានទិន្នន័យ។

ឃ- អ្នកទទួលទិន្នន័យបុគ្គល។

ង- សិទ្ធិក្នុងការប្តឹងតវ៉ាទៅក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

ច- របៀបប្រើប្រាស់សិទ្ធិរបស់ប្រធានទិន្នន័យដូចមានចែងក្នុងជំពូកនេះ។

ឆ- ព័ត៌មានផ្សេងទៀតដែលចាំបាច់ដើម្បីធានាថា ទិន្នន័យបុគ្គលត្រូវបានធ្វើប្រព្រឹត្តកម្មដោយសមភាព និងតម្លាភាព។

ព័ត៌មានដូចមានចែងពីចំណុច ក ដល់ចំណុច ឆ នៃកថាខណ្ឌទី១ ខាងលើនេះ ក៏ត្រូវយកមកអនុវត្តផងដែរ ក្នុងករណីដែលបុគ្គលគ្រប់គ្រងទិន្នន័យទទួលបានទិន្នន័យបុគ្គលរបស់ប្រធានទិន្នន័យពីបុគ្គលដែលមិនមែនជាប្រធានទិន្នន័យ។ ក្នុងករណីនេះ បុគ្គលគ្រប់គ្រងទិន្នន័យត្រូវផ្តល់ព័ត៌មានទៅប្រធានទិន្នន័យភ្លាម និងមិនឱ្យហួសពីរយៈពេល ១ (មួយ) ខែ បន្ទាប់ពីថ្ងៃដែលទទួលបានទិន្នន័យបុគ្គលនោះ។

មាត្រា២៨ .. សិទ្ធិអាក់សេសទិន្នន័យបុគ្គល

ប្រធានទិន្នន័យមានសិទ្ធិអាក់សេស ឬមានសិទ្ធិទទួលបានច្បាប់ចម្លងនៃទិន្នន័យបុគ្គលរបស់ខ្លួនពីបុគ្គលគ្រប់គ្រងទិន្នន័យ ព្រមទាំងព័ត៌មានពាក់ព័ន្ធនឹងការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលរបស់ខ្លួននោះ។

ក្នុងករណីដែលទិន្នន័យបុគ្គលត្រូវបានផ្ទេរទៅក្រៅព្រះរាជាណាចក្រកម្ពុជា ប្រធានទិន្នន័យត្រូវមានសិទ្ធិទទួលបានព័ត៌មានអំពីវិធានការការពារសមរម្យ ដូចមានចែងក្នុងចំណុច ខ នៃមាត្រា២៣ នៃច្បាប់នេះ។

មាត្រា២៩ .. សិទ្ធិកែតម្រូវទិន្នន័យបុគ្គល

ប្រធានទិន្នន័យមានសិទ្ធិទទួលបានការកែតម្រូវភ្លាមដោយគ្មានការពន្យារពេល ចំពោះទិន្នន័យបុគ្គលដែលមិនត្រឹមត្រូវឬមិនពេញលេញពីបុគ្គលគ្រប់គ្រងទិន្នន័យ។ ក្នុងករណីនេះប្រធានទិន្នន័យមានសិទ្ធិបំពេញបន្ថែមនូវទិន្នន័យបុគ្គលរបស់ខ្លួនដែលមិនទាន់ពេញលេញ រួមទាំងការផ្តល់សេចក្តីថ្លែងការណ៍បន្ថែមផងដែរ។

ដើម្បីជានាការអនុវត្តសិទ្ធិដូចមានចែងក្នុង កថាខណ្ឌទី១ ខាងលើនេះ បុគ្គលគ្រប់គ្រងទិន្នន័យត្រូវជូនដំណឹងទៅប្រធានទិន្នន័យអំពីការកែតម្រូវទិន្នន័យដែលមិនត្រឹមត្រូវ ឬទិន្នន័យដែលមិនពេញលេញ លើកលែងតែមានហេតុផលបញ្ជាក់ថាការជូនដំណឹងនេះមិនអាចធ្វើបាន ឬលើសពីសមត្ថភាពក្នុងការជូនដំណឹង។

មាត្រា៣០ .. សិទ្ធិលុបចោលទិន្នន័យបុគ្គល

ប្រធានទិន្នន័យមានសិទ្ធិទាមទារឱ្យបុគ្គលគ្រប់គ្រងទិន្នន័យលុបទិន្នន័យបុគ្គលរបស់ខ្លួនភ្លាម ដោយគ្មានការពន្យារពេល ផ្អែកតាមមូលហេតុណាមួយ ដូចខាងក្រោម ៖

ក- ទិន្នន័យបុគ្គលលែងមានភាពចាំបាច់សម្រាប់គោលបំណងនៃការធ្វើប្រព្រឹត្តកម្មបន្តទៀត។

ខ- ប្រធានទិន្នន័យបានដកការយល់ព្រមចំពោះការធ្វើប្រព្រឹត្តកម្ម ដូចមានចែងក្នុងចំណុច ក នៃមាត្រា៧ នៃច្បាប់នេះ ហើយបុគ្គលគ្រប់គ្រងទិន្នន័យមិនមានមូលដ្ឋានគតិយុត្តផ្សេងទៀតក្នុងការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលផ្សេងទៀត។

គ- ប្រធានទិន្នន័យជំទាស់ចំពោះការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលរបស់ខ្លួន ស្របតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា៣៣ នៃច្បាប់នេះហើយមិនមានមូលដ្ឋានគតិយុត្តណាមួយលើសលប់សម្រាប់ការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលនោះ។

ឃ- ទិន្នន័យបុគ្គលត្រូវបានធ្វើប្រព្រឹត្តកម្មផ្ទុយនឹងច្បាប់នេះ ឬច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

ង- ច្បាប់ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតតម្រូវឱ្យលុបទិន្នន័យបុគ្គលនោះ។

ក្នុងករណីដែលបុគ្គលគ្រប់គ្រងទិន្នន័យបានផ្សព្វផ្សាយជាសាធារណៈនូវទិន្នន័យបុគ្គលដែលតម្រូវឱ្យលុបដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ បុគ្គលគ្រប់គ្រងទិន្នន័យត្រូវចាត់វិធានការសមរម្យ ដើម្បីលុបទិន្នន័យបុគ្គលដែលបានផ្សព្វផ្សាយជាសាធារណៈនោះដោយជូនដំណឹងទៅបុគ្គលគ្រប់គ្រងទិន្នន័យផ្សេងទៀតឱ្យលុបនូវរាល់តំណភ្ជាប់ ឬច្បាប់ចម្លងនៃទិន្នន័យបុគ្គលដែលបានស្នើសុំឱ្យលុបនោះ។ ក្នុងការចាត់វិធានការសមរម្យ បុគ្គលគ្រប់គ្រងទិន្នន័យអាចគិតគូរអំពីការប្រើប្រាស់បច្ចេកវិទ្យាដែលមាន និងការចំណាយក្នុងការលុបទិន្នន័យបុគ្គលនោះ។

បទប្បញ្ញត្តិដែលមានចែងក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី២ ខាងលើនេះមិនត្រូវយកមកអនុវត្តក្នុងករណីណាមួយដូចខាងក្រោម៖

ក- ការអនុវត្តសិទ្ធិសេរីភាពនៃការបញ្ចេញមតិ និងសិទ្ធិទទួលព័ត៌មាន។

ខ- ការអនុវត្តកាតព្វកិច្ចតាមផ្លូវច្បាប់របស់បុគ្គលគ្រប់គ្រងទិន្នន័យ ឬសម្រាប់បំពេញភារកិច្ចក្នុងផលប្រយោជន៍សាធារណៈ ឬការអនុវត្តសិទ្ធិអំណាចតាមច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តដែលផ្តល់ឱ្យបុគ្គលគ្រប់គ្រងទិន្នន័យ។

គ- ការធ្វើប្រព្រឹត្តកម្មមានភាពចាំបាច់សម្រាប់គោលបំណងសុខភាពសាធារណៈ។

ឃ- ការធ្វើប្រព្រឹត្តកម្មមានភាពចាំបាច់សម្រាប់បំណងរក្សាទុកក្នុងបណ្ណសារជាផលប្រយោជន៍សាធារណៈ ឬការស្រាវជ្រាវបែបវិទ្យាសាស្ត្រ ឬប្រវត្តិសាស្ត្រ ឬស្ថិតិ ស្របតាមគោលការណ៍ណែនាំរួមស្តីពីកិច្ចការពារទិន្នន័យបុគ្គល។

ង- ការធ្វើប្រព្រឹត្តកម្មមានភាពចាំបាច់សម្រាប់ការបង្កើតសិទ្ធិតាមផ្លូវច្បាប់ ការអនុវត្តសិទ្ធិតាមផ្លូវច្បាប់ ឬការការពារសិទ្ធិតាមផ្លូវច្បាប់។

ដើម្បីធានាការអនុវត្តសិទ្ធិដូចមានចែងក្នុង មាត្រានេះ បុគ្គលគ្រប់គ្រងទិន្នន័យត្រូវជូនដំណឹងទៅប្រធានទិន្នន័យអំពីការលុបចោលទិន្នន័យបុគ្គល លើកលែងតែមានហេតុផលបញ្ជាក់ថាការជូនដំណឹងនេះមិនអាចធ្វើបាន ឬលើសពីសមត្ថភាពក្នុងការជូនដំណឹង។

មាត្រា៣១ .. សិទ្ធិរឹតត្បិតទិន្នន័យបុគ្គល

ប្រធានទិន្នន័យមានសិទ្ធិទាមទារឱ្យ បុគ្គលគ្រប់គ្រងទិន្នន័យដាក់កម្រិតចំពោះការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលរបស់ខ្លួន ក្នុងលក្ខខណ្ឌណាមួយដូចខាងក្រោម៖

ក- ការតវ៉ាពីប្រធានទិន្នន័យអំពីសុក្រឹតភាពនៃទិន្នន័យបុគ្គល ហើយទុករយៈពេលឱ្យបុគ្គលគ្រប់គ្រងទិន្នន័យពិនិត្យផ្ទៀងផ្ទាត់អំពីសុក្រឹតភាពនៃទិន្នន័យបុគ្គលនោះ។

ខ- ការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលផ្ទុយនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ប៉ុន្តែប្រធានទិន្នន័យ ដំទាស់នឹងការលុបចោលទិន្នន័យបុគ្គលនោះ ដោយស្នើសុំឱ្យបុគ្គលគ្រប់គ្រងទិន្នន័យដាក់កម្រិតលើការប្រើប្រាស់ទិន្នន័យបុគ្គលនោះជំនួសវិញ។

គ- បុគ្គលគ្រប់គ្រងទិន្នន័យលែងត្រូវការទិន្នន័យបុគ្គលសម្រាប់ធ្វើប្រព្រឹត្តកម្មទិន្នន័យ ប៉ុន្តែប្រធានទិន្នន័យស្នើសុំឱ្យរក្សាទុកទិន្នន័យបុគ្គលនោះ សម្រាប់ការបង្កើតសិទ្ធិតាមផ្លូវច្បាប់ ការអនុវត្តសិទ្ធិតាមផ្លូវច្បាប់ ឬការការពារសិទ្ធិតាមផ្លូវច្បាប់។

ឃ- ប្រធានទិន្នន័យអនុវត្តសិទ្ធិបដិសេធ ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រា៣៣ នៃច្បាប់នេះ។

ក្នុងករណីមានការដាក់កម្រិតចំពោះការធ្វើប្រព្រឹត្តកម្ម ដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ ការធ្វើប្រព្រឹត្តកម្មទិន្នន័យត្រូវបានហាមឃាត់ក្នុងអំឡុងពេលដែលមានការរឹតត្បិត លើកលែងតែករណីណាមួយ ដូចខាងក្រោម៖

ក- ការយល់ព្រមពីប្រធានទិន្នន័យឱ្យធ្វើប្រព្រឹត្តកម្ម។

ខ- ភាពចាំបាច់សម្រាប់ការបង្កើតសិទ្ធិតាមផ្លូវច្បាប់ ការអនុវត្តសិទ្ធិតាមផ្លូវច្បាប់ ឬការការពារសិទ្ធិតាមផ្លូវច្បាប់។

គ- ភាពចាំបាច់សម្រាប់ការការពារសិទ្ធិរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលផ្សេងទៀត។

ឃ- ភាពចាំបាច់សម្រាប់ផលប្រយោជន៍សាធារណៈ។

ដើម្បីធានាការអនុវត្តសិទ្ធិដូចមានចែងក្នុង កថាខណ្ឌទី១ ខាងលើនេះ បុគ្គលគ្រប់គ្រងទិន្នន័យត្រូវជូនដំណឹងទៅប្រធានទិន្នន័យអំពីការរឹតត្បិតទិន្នន័យបុគ្គល លើកលែងតែមានហេតុផលបញ្ជាក់ថាការជូនដំណឹងនេះមិនអាចធ្វើបាន ឬលើសពីសមត្ថភាពក្នុងការជូនដំណឹង។

មាត្រា៣២ ៖ សិទ្ធិផ្លាស់ទីទិន្នន័យបុគ្គល

ប្រធានទិន្នន័យមានសិទ្ធិស្នើសុំឱ្យបុគ្គលគ្រប់គ្រងដែលកំពុងរក្សាទុកទិន្នន័យបុគ្គលរបស់ខ្លួនផ្លាស់ទីទិន្នន័យបុគ្គលនោះទៅឱ្យបុគ្គលគ្រប់គ្រងទិន្នន័យផ្សេងទៀត។ បុគ្គលគ្រប់គ្រងទិន្នន័យដែលត្រូវបានស្នើសុំ មានកាតព្វកិច្ចផ្លាស់ទីទិន្នន័យបុគ្គលនោះ ក្នុងទម្រង់ដែលអាចអានបានដោយម៉ាស៊ីន ទៅបុគ្គលគ្រប់គ្រងទិន្នន័យដែលទទួលទិន្នន័យបុគ្គលនោះ តាមការស្នើសុំរបស់ប្រធានទិន្នន័យ ដោយគ្មានការរារាំង ផ្អែកតាមលក្ខខណ្ឌដូចខាងក្រោម៖

ក- ការធ្វើប្រព្រឹត្តកម្មធ្វើឡើងដោយមានការយល់ព្រមពីប្រធានទិន្នន័យ ដោយអនុលោមតាមច្បាប់នេះ ឬតាមកិច្ចសន្យា។

ខ- ការធ្វើប្រព្រឹត្តកម្មទិន្នន័យត្រូវបានអនុវត្តតាមមធ្យោបាយស្វ័យប្រវត្តិកម្ម។

ក្នុងករណីដែលប្រធានទិន្នន័យអនុវត្តសិទ្ធិតាមកថាខណ្ឌទី១ ខាងលើនេះ ប្រធានទិន្នន័យមានសិទ្ធិផ្លាស់ទីទិន្នន័យដោយផ្ទាល់ពីបុគ្គលគ្រប់គ្រងទិន្នន័យមួយទៅបុគ្គលគ្រប់គ្រងទិន្នន័យមួយទៀត ប្រសិនបើបច្ចេកទេសអាចធ្វើបាន។

ការអនុវត្តសិទ្ធិក្នុងការផ្លាស់ទីទិន្នន័យដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ មិនត្រូវប៉ះពាល់ដល់សិទ្ធិលុបទិន្នន័យបុគ្គលដូចមានចែងក្នុងមាត្រា៣១ នៃច្បាប់នេះ និងសិទ្ធិនិងសេរីភាពរបស់រូបវន្តបុគ្គលដទៃទៀតឡើយ។

សិទ្ធិផ្លាស់ទីទិន្នន័យមិនអាចអនុវត្តបានឡើយ ក្នុងករណីដែលបុគ្គលគ្រប់គ្រងទិន្នន័យធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គល ដោយអនុលោមតាមចំណុច ង នៃមាត្រា៧ និងមាត្រា១២ នៃច្បាប់នេះ។

មាត្រា៣៣ ៖ សិទ្ធិបដិសេធ

ប្រធានទិន្នន័យមានសិទ្ធិបដិសេធចំពោះការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គល នៅពេលណាមួយក៏បានដោយផ្អែកលើមូលហេតុដែលពាក់ព័ន្ធនឹងស្ថានភាពរបស់ខ្លួន និងប្រសិនបើមានលក្ខខណ្ឌណាមួយដូចខាងក្រោម៖

ក- ការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលផ្អែកលើភាពចាំបាច់សម្រាប់គោលបំណងនៃការបំពេញភារកិច្ចក្នុងផលប្រយោជន៍សាធារណៈ ដូចមានចែងក្នុងចំណុច ង នៃមាត្រា៧ និងមាត្រា១២ នៃច្បាប់នេះ។

ខ- ការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលផ្អែកលើភាពចាំបាច់សម្រាប់គោលបំណងនៃផលប្រយោជន៍ធម្មានុរូបរបស់បុគ្គលគ្រប់គ្រងទិន្នន័យ ឬតតិយជន ដូចមានចែងក្នុងចំណុច ច នៃមាត្រា៧ និងមាត្រា១៣ នៃច្បាប់នេះ។

ក្នុងករណីដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ ប្រធានទិន្នន័យអាចអនុវត្តសិទ្ធិបដិសេធដើម្បីបញ្ឈប់ឬរារាំងការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលរបស់ខ្លួន។ ក្នុងករណីនេះបុគ្គលគ្រប់គ្រងទិន្នន័យអាចបន្តការធ្វើប្រព្រឹត្តកម្មទិន្នន័យបាន ប្រសិនបុគ្គលគ្រប់គ្រងទិន្នន័យអាចបង្ហាញថា ការធ្វើប្រព្រឹត្តកម្មទិន្នន័យមានហេតុផលធម្មានុរូបរឹងមាំ ដែលលើសលប់សិទ្ធិមូលដ្ឋាន និងសេរីភាពរបស់ប្រធានទិន្នន័យ ឬប្រសិនបើការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលនោះមានភាពចាំបាច់សម្រាប់ការបង្កើតសិទ្ធិ ការអនុវត្តសិទ្ធិ ឬការការពារសិទ្ធិតាមផ្លូវច្បាប់។

ក្រៅពីនេះ ប្រធានទិន្នន័យមានសិទ្ធិដាច់ខាតក្នុងការបដិសេធការប្រើប្រាស់ទិន្នន័យបុគ្គលរបស់ខ្លួន សម្រាប់គោលបំណងផ្សព្វផ្សាយពាណិជ្ជកម្មទាំងស្រុង។

មាត្រា៣៤ .. សិទ្ធិទាមទារឱ្យមានការចូលរួមរបស់មនុស្ស ក្នុងករណីការធ្វើប្រព្រឹត្តកម្ម ទិន្នន័យបុគ្គលដោយស្វ័យប្រវត្តិរួមទាំងការខាយតម្លៃលើប្រធានទិន្នន័យ

ប្រធានទិន្នន័យមានសិទ្ធិទាមទារឱ្យមានការចូលរួមរបស់មនុស្សក្នុងករណីការសម្រេចដោយស្វ័យប្រវត្តិដែលនាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់ ឬផលប៉ះពាល់ប្រហាក់ប្រហែលរបស់ខ្លួន។

សិទ្ធិទាមទារឱ្យមានការចូលរួមរបស់មនុស្សក្នុងករណីការសម្រេចដោយស្វ័យប្រវត្តិដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចអនុវត្តបានឡើយ ប្រសិនបើការសម្រេចដោយស្វ័យប្រវត្តិនោះ៖

ក- មានភាពចាំបាច់នៃការអនុវត្តកិច្ចសន្យា ឬការផ្តួចផ្តើមឱ្យមានការចុះកិច្ចសន្យា។

ខ- មានការអនុញ្ញាតដោយច្បាប់ជាក់លាក់។ ឬ

គ- មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីប្រធានទិន្នន័យ។

ក្នុងករណីដូចមានចែងក្នុងចំណុច ក ចំណុច ខ និងចំណុច គ នៃកថាខណ្ឌទី២ នៃច្បាប់នេះ បុគ្គលគ្រប់គ្រងទិន្នន័យត្រូវអនុវត្តវិធានការសមស្របដើម្បីការពារសិទ្ធិ សេរីភាព និងផលប្រយោជន៍ស្របច្បាប់របស់ប្រធានទិន្នន័យ។ វិធានការនេះរួមបញ្ចូលទាំងសិទ្ធិទាមទារឱ្យមានការចូលរួមរបស់មនុស្ស ព្រមទាំងផ្តល់សិទ្ធិឱ្យប្រធានទិន្នន័យអាចបញ្ចេញមតិ ឬបដិសេធចំពោះការសម្រេចដោយស្វ័យប្រវត្តិនោះ។

មាត្រា៣៥ .. សិទ្ធិទទួលបានដំណោះស្រាយ

ប្រធានទិន្នន័យមានសិទ្ធិទទួលបានដំណោះស្រាយត្រឹមត្រូវតាមច្បាប់ នៅពេលដែលសិទ្ធិរបស់ខ្លួនត្រូវបានបំពាន ដូចមានចែងក្នុងជំពូកនេះ។

បុគ្គលគ្រប់គ្រងទិន្នន័យត្រូវបង្កើត និងកំណត់វិធាន និងយន្តការបណ្តឹងនិងដោះស្រាយវិវាទ នៅក្នុងបទបញ្ជាផ្ទៃក្នុងស្តីពីកិច្ចការពារទិន្នន័យបុគ្គលរបស់ខ្លួន។

មាត្រា៣៦ .. លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការអនុវត្តសិទ្ធិរបស់ប្រធានទិន្នន័យ

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការអនុវត្តសិទ្ធិរបស់ប្រធានទិន្នន័យដូចមានចែងក្នុងជំពូកនេះ ត្រូវកំណត់ក្នុងគោលការណ៍ណែនាំរួមស្តីពីកិច្ចការពារទិន្នន័យបុគ្គល។

ជំពូកទី៧
គោលការណ៍ណែនាំស្តីពីកិច្ចការពារទិន្នន័យបុគ្គល

មាត្រា៣៧ .. គោលការណ៍ណែនាំរួមស្តីពីកិច្ចការពារទិន្នន័យបុគ្គល

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវរៀបចំគោលការណ៍ណែនាំរួមស្តីពីកិច្ចការពារទិន្នន័យបុគ្គលដើម្បីសុំការសម្រេចពីរាជរដ្ឋាភិបាល។

គោលការណ៍ណែនាំរួមស្តីពីកិច្ចការពារទិន្នន័យបុគ្គលត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា៣៨ .. គោលការណ៍ណែនាំបន្ថែមស្តីពីកិច្ចការពារទិន្នន័យបុគ្គលតាមវិស័យ

ក្រសួង ស្ថាប័នទទួលបន្ទុកតាមវិស័យ អាចរៀបចំគោលការណ៍ណែនាំបន្ថែមស្តីពីកិច្ចការពារទិន្នន័យបុគ្គលតាមវិស័យ ប្រសិនបើចាំបាច់។ ការរៀបចំគោលការណ៍ណែនាំបន្ថែមស្តីពីកិច្ចការពារទិន្នន័យបុគ្គលតាមវិស័យត្រូវអនុលោមតាមគោលការណ៍ណែនាំរួមស្តីពីកិច្ចការពារទិន្នន័យបុគ្គល និងពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

គោលការណ៍ណែនាំបន្ថែមស្តីពីកិច្ចការពារទិន្នន័យបុគ្គលតាមវិស័យនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័នទទួលបន្ទុកតាមវិស័យ។

មាត្រា៣៩ .. បទឧបញ្ញាផ្ទៃក្នុងស្តីពីកិច្ចការពារទិន្នន័យបុគ្គល

បុគ្គលគ្រប់គ្រងទិន្នន័យ និងបុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យត្រូវរៀបចំបទបញ្ជាផ្ទៃក្នុងស្តីពីកិច្ចការពារទិន្នន័យបុគ្គលដោយអនុលោមតាមគោលការណ៍ណែនាំរួមស្តីពីកិច្ចការពារទិន្នន័យបុគ្គល និងគោលការណ៍ណែនាំបន្ថែមស្តីពីកិច្ចការពារទិន្នន័យបុគ្គលតាមវិស័យ ប្រសិនបើមាន។

បទបញ្ជាផ្ទៃក្នុងស្តីពីកិច្ចការពារទិន្នន័យបុគ្គលត្រូវសម្រេចដោយគណៈគ្រប់គ្រង ឬថ្នាក់ដឹកនាំជាន់ខ្ពស់នៃបុគ្គលគ្រប់គ្រងទិន្នន័យ និងបុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ។

បទបញ្ជាផ្ទៃស្តីពីកិច្ចការពារទិន្នន័យបុគ្គល ត្រូវរួមបញ្ចូលវិធានការបច្ចេកទេស និងវិធានការគ្រប់គ្រងទិន្នន័យបុគ្គល ដោយពិចារណាអំពីទម្រង់ដែលធានាសន្តិសុខនៃទិន្នន័យបុគ្គល ប្រភេទ វិសាលភាព បរិបទ និងគោលបំណងនៃការធ្វើប្រព្រឹត្តកម្ម ព្រមទាំងហានិភ័យដែលអាចនាំឱ្យប៉ះពាល់ដល់សិទ្ធិ និងសេរីភាពរបស់ប្រធានទិន្នន័យ។

បុគ្គលគ្រប់គ្រងទិន្នន័យត្រូវតែអាចបង្ហាញថា វិធានការបច្ចេកទេស និងវិធានការគ្រប់គ្រងទិន្នន័យបុគ្គលអនុលោមតាមច្បាប់នេះ។

បុគ្គលគ្រប់គ្រងទិន្នន័យត្រូវត្រួតពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្មវិធានការបច្ចេកទេស និងវិធានការគ្រប់គ្រងទិន្នន័យបុគ្គលរបស់ខ្លួន ផ្អែកតាមការផ្លាស់ប្តូរប្រតិបត្តិការធុរកិច្ចរបស់ខ្លួន ការវិវត្តនៃបច្ចេកវិទ្យា ការផ្លាស់ប្តូរនៃច្បាប់ និងការកំណត់របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

ជំពូកទី៨
អធិការកិច្ចទិន្នន័យបុគ្គល

មាត្រា៤០ .. មន្ត្រីអធិការកិច្ចទិន្នន័យបុគ្គល/ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវចាត់តាំងមន្ត្រីអធិការកិច្ចទិន្នន័យបុគ្គល/ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដើម្បីតាមដាន ស៊ើបអង្កេត ប្រមូលភស្តុតាង និងជំរុញការអនុវត្តច្បាប់នេះ។

មន្ត្រីអធិការកិច្ចទិន្នន័យបុគ្គល/ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ឱ្យពិនិត្យបទល្មើសដូចមានចែងក្នុងច្បាប់នេះ ដោយអនុវត្តឱ្យស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

បែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ចំពោះមន្ត្រីអធិការកិច្ចទិន្នន័យបុគ្គល/ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

មាត្រា៤១ .. ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទិន្នន័យបុគ្គល/ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

ក្នុងពេលប្រតិបត្តិការអនុវត្តច្បាប់ មន្ត្រីអធិការកិច្ចទិន្នន័យបុគ្គល/ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវស្លៀកពាក់ឯកសណ្ឋាន មានសញ្ញាសម្គាល់និងសញ្ញាសក្តិ និងមានលិខិតបញ្ជាបេសកកម្ម។

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទិន្នន័យបុគ្គល/ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា៤២ .. តារាកិច្ចនិងសិទ្ធិរបស់មន្ត្រីអធិការកិច្ចទិន្នន័យបុគ្គល/ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

មន្ត្រីអធិការកិច្ចទិន្នន័យបុគ្គល/ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ មានការកិច្ចនិងសិទ្ធិដូចខាងក្រោម៖

ក- តាមដាន ស៊ើបអង្កេត និងបង្ក្រាបអំពើបទល្មើសពាក់ព័ន្ធនឹងកិច្ចការពារទិន្នន័យបុគ្គល។

ខ- ចាត់វិធានការដែលអនុលោមតាមច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

គ- ចាប់យកវត្ថុតាងនិងកសាងសំណុំរឿងនៃបទល្មើសនឹងច្បាប់នេះ។

ឃ- បំពេញការកិច្ចនិងចាត់វិធានការផ្សេងទៀតនៅក្នុងក្របខណ្ឌនៃការអនុវត្តច្បាប់នេះ ឬតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

បែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចទិន្នន័យបុគ្គល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

មាត្រា៤៣ .. អធិការកិច្ចទិន្នន័យបុគ្គល

រាល់ការធ្វើអធិការកិច្ចទិន្នន័យបុគ្គលក្នុងការពិនិត្យបទល្មើសត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

មន្ត្រីអធិការកិច្ចទិន្នន័យបុគ្គល/ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ អាចស្នើសុំជំនួយពីអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមបង្ក្រាបបទល្មើសដូចមានចែងក្នុងច្បាប់នេះ។

ក្នុងករណីបទល្មើសជាក់ស្តែង អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវផ្តល់ព័ត៌មានជាបន្ទាន់ដល់មន្ត្រីអធិការកិច្ចទិន្នន័យបុគ្គល/ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ដែលនៅជិតបំផុត ដើម្បីចាត់វិធានការតាមនីតិវិធី។

មាត្រា៤៤ .. ការប្តឹងឧទ្ធរណ៍ចំពោះវិធានការរបស់មន្ត្រីអធិការកិច្ចទិន្នន័យបុគ្គល/ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

បុគ្គលណាដែលមិនសុខចិត្តចំពោះវិធានការណាមួយរបស់មន្ត្រីអធិការកិច្ចទិន្នន័យបុគ្គល/ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ អាចប្តឹងតវ៉ាទៅក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេច។

រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបណ្តឹង។

ក្នុងករណីបុគ្គលនោះមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បុគ្គលនោះមានសិទ្ធិធ្វើបណ្តឹងទៅយន្តការផ្សេងទៀតរបស់រាជរដ្ឋាភិបាល ឬទៅតុលាការតាមនីតិវិធី។

ជំពូកទី៩
ការដោះស្រាយវិវាទ

មាត្រា៤៥ .. ការដោះស្រាយវិវាទពាក់ព័ន្ធនឹងកិច្ចការពារទិន្នន័យបុគ្គល

ក្រៅពីករណីបទល្មើសព្រហ្មទណ្ឌ គ្រប់វិវាទដែលពាក់ព័ន្ធនឹងកិច្ចការពារទិន្នន័យបុគ្គល ភាគីវិវាទត្រូវដាក់ពាក្យបណ្តឹងទៅក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដើម្បីដោះស្រាយតាមនីតិវិធីជាធរមាន។ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវចាត់តាំងអ្នកផ្សះផ្សាម្នាក់ ក្នុងរយៈពេល ៤៨ (សែសិបប្រាំបី) ម៉ោងគិតចាប់ពីពេលបានទទួលពាក្យបណ្តឹង ដើម្បីធ្វើការផ្សះផ្សាឬដោះស្រាយ។

ក្នុងករណីដែលមានគូភាគីពុំបានដាក់ពាក្យបណ្តឹងមកក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក៏អាចផ្សះផ្សាឬដោះស្រាយផងដែរ ប្រសិនបើចាំបាច់។

ការផ្សះផ្សាឬដោះស្រាយវិវាទដែលពាក់ព័ន្ធនឹងកិច្ចការពារទិន្នន័យបុគ្គល ត្រូវធ្វើក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីពេលបានទទួលសេចក្តីបង្គាប់ពីរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

លទ្ធផលនៃការផ្សះផ្សា ត្រូវចុះក្នុងរបាយការណ៍ផ្សះផ្សាវិវាទ។ របាយការណ៍ផ្សះផ្សាវិវាទនេះ ត្រូវចុះពីចំណុចដែលបានសះជានិង/ឬចំណុចដែលមិនបានសះជា ហើយត្រូវចុះហត្ថលេខាដោយគូភាគីវិវាទនិងមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវផ្តល់សេចក្តីចម្លងរបាយការណ៍ផ្សះផ្សាវិវាទ ជូនគូភាគីវិវាទក្នុងមួយនាក់មួយច្បាប់។

ចំណុចដែលបានសះជាមានអានុភាពអនុវត្តភ្លាម ឬតាមការកំណត់ក្នុងរបាយការណ៍ផ្សះផ្សាវិវាទ។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការដោះស្រាយវិវាទកិច្ចការពារទិន្នន័យបុគ្គល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

មាត្រា៤៦ .. កម្រៃសេវាសាធារណៈសម្រាប់ការដោះស្រាយវិវាទ

កម្រៃសេវាសាធារណៈសម្រាប់ការដោះស្រាយវិវាទត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

ជំពូកទី១០
ទោសប្បញ្ញត្តិ

មាត្រា៤៧ .. ទណ្ឌកម្ម

ទណ្ឌកម្មក្នុងច្បាប់នេះរួមមាន៖

ក- ទណ្ឌកម្មរដ្ឋបាល រួមមានការព្រមានជាលាយលក្ខណ៍អក្សរ ការផាកពិន័យ ការដាក់កំហិត និងទណ្ឌកម្មរដ្ឋបាលផ្សេងទៀត។ ការដាក់ទណ្ឌកម្មរដ្ឋបាល ត្រូវស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។ វិធាននិងនីតិវិធីក្នុងការអនុវត្តទណ្ឌកម្មរដ្ឋបាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

ខ- ទណ្ឌកម្មព្រហ្មទណ្ឌ រួមមានទណ្ឌកម្មព្រហ្មទណ្ឌដូចមានចែងក្នុងមាត្រា៥១ នៃច្បាប់នេះ។

មាត្រា៤៨ ៖ ការផាកពិន័យ

ត្រូវផាកពិន័យជាប្រាក់ចំពោះបុគ្គលដែលបំពានបទប្បញ្ញត្តិណាមួយក្នុងជំពូកទី៣ ជំពូកទី៤ ជំពូកទី៥ ឬ ជំពូកទី៦ នៃច្បាប់នេះ ដូចខាងក្រោម៖

- មិនលើសពី ៦០ ០០០ ០០០ (ហុកសិបលាន) រៀល ចំពោះរូបវន្តបុគ្គលម្នាក់ៗដែលជាប់ពាក់ព័ន្ធ
- មិនលើសពី ៦០០ ០០០ ០០០ (ប្រាំមួយរយលាន) រៀល ឬ១០% នៃចំណូលប្រចាំឆ្នាំ ចំពោះនីតិបុគ្គលនីមួយៗដែលជាប់ពាក់ព័ន្ធ។

ចំណូលប្រចាំឆ្នាំរបស់នីតិបុគ្គលត្រូវកំណត់យកចំណូលដែលមានក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច ដោយសវនករឯករាជ្យដែលទទួលស្គាល់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា៤៩ ៖ មូលដ្ឋាននៃការផាកពិន័យ

ការសម្រេចផាកពិន័យជាប្រាក់ ដូចមានចែងក្នុងមាត្រា៤៨ នៃច្បាប់នេះ ត្រូវធ្វើឡើងដោយផ្អែកលើមូលដ្ឋាន ដូចខាងក្រោម៖

ក- លក្ខណៈ ទម្ងន់ និងរយៈពេលនៃការបំពានច្បាប់របស់បុគ្គលគ្រប់គ្រងទិន្នន័យ។

ខ- ប្រភេទ និងលក្ខណៈនៃទិន្នន័យបុគ្គលដែលទទួលរងផលប៉ះពាល់ពីការបំពានច្បាប់របស់បុគ្គលគ្រប់គ្រងទិន្នន័យ។

គ- ការទទួលបានប្រាក់ចំណូល ឬជៀសវាងការខាតបង់ផ្ទែកហិរញ្ញវត្ថុដែលបណ្តាលមកពីការបំពានច្បាប់របស់បុគ្គលគ្រប់គ្រងទិន្នន័យ។

ឃ- ការចាត់វិធានការឱ្យបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពរបស់បុគ្គលគ្រប់គ្រងទិន្នន័យ ដើម្បីកាត់បន្ថយផលប៉ះពាល់និងផលវិបាកនៃការបំពានច្បាប់។

ង- បុគ្គលគ្រប់គ្រងទិន្ននន័យបានព្យាយាមអនុវត្តវិធានការសមស្រប និងសមរម្យរួចហើយ ប៉ុន្តែនៅតែមានការបំពានច្បាប់។

ច- ការបំពានច្បាប់កន្លងមករបស់បុគ្គលគ្រប់គ្រងទិន្នន័យ។

ឆ- ការអនុវត្តតាមបទបញ្ជា ឬគោលការណ៍ណែនាំរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ឬការអនុវត្តដោយស្ម័គ្រចិត្តរបស់បុគ្គលគ្រប់គ្រងទិន្នន័យពាក់ព័ន្ធនឹងសំណង ឬកាត់បន្ថយផលប៉ះពាល់ដោយការបំពានច្បាប់។

ជ- ការផាកពិន័យជាប្រាក់មានភាពសមាមាត្រនិងប្រសិទ្ធភាព ដើម្បីពង្រឹងការអនុវត្តច្បាប់ និងទប់ស្កាត់ការបំពានច្បាប់របស់បុគ្គលគ្រប់គ្រងទិន្នន័យ។

ឈ- ផលប៉ះពាល់ពីការផាកពិន័យជាប្រាក់ មកលើបុគ្គលគ្រប់គ្រងទិន្នន័យឬប្រតិបត្តិការជាប្រចាំរបស់បុគ្គលគ្រប់គ្រងទិន្នន័យ។

ញ- មូលដ្ឋានពាក់ព័ន្ធផ្សេងទៀតដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មាត្រា៥០ ៖ ការផាកពិន័យ ក្នុងករណីមិនបានបង់ប្រាក់ផាកពិន័យ

បុគ្គលដែលត្រូវបានផាកពិន័យជាប្រាក់ ហើយមិនបានបង់ប្រាក់ផាកពិន័យក្នុងរយៈពេលលើសពី៖

១- ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានលិខិតបង្គាប់ឱ្យបង់ប្រាក់ផាកពិន័យ ត្រូវទទួលការផាកពិន័យជាប្រាក់ពីរដងនៃចំនួនទឹកប្រាក់ផាកពិន័យ ដែលមិនទាន់បានបង់។

២- ៦០ (ហុកសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានលិខិតបង្គាប់ឱ្យបង់ប្រាក់ផាកពិន័យ ត្រូវទទួលការផាកពិន័យជាប្រាក់បីដងនៃចំនួនទឹកប្រាក់ផាកពិន័យ ដែលមិនទាន់បានបង់។

៣- ៩០ (កៅសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានលិខិតបង្គាប់ឱ្យបង់ប្រាក់ផាកពិន័យ ត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការមានសមត្ថកិច្ច ដើម្បីចាត់ការតាមនីតិវិធី។

មាត្រា៥១ .. ការទទួលខុសត្រូវព្រហ្មទណ្ឌ

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា៤៨ នៃច្បាប់នេះ។

រូបវន្តបុគ្គលដែលនៅតែប្រព្រឹត្តល្មើសដដែល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦ (ប្រាំមួយ) ថ្ងៃ ទៅ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់មិនលើសពី ៦០ ០០០ ០០០ (ហុកសិបលាន) រៀល។

នីតិបុគ្គលដែលនៅតែប្រព្រឹត្តបទល្មើសដដែល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់មិនលើសពី ១០០ ០០០ ០០០ (មួយរយលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចមានចែងក្នុងមាត្រា១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ។

ជំពូកទី១១
អន្តរប្បញ្ញត្តិ

មាត្រា៥២ ..

លិខិតបទដ្ឋានគតិយុត្តទាំងឡាយពាក់ព័ន្ធនឹងកិច្ចការពារទិន្នន័យបុគ្គល ដែលមានជាធរមានកន្លងមក ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

ជំពូកទី១២
អវសានប្បញ្ញត្តិ

មាត្រា៥៣ ..

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

មាត្រា៥៤ ..

ច្បាប់នេះត្រូវយកទៅអនុវត្ត ក្នុងរយៈពេល ២ (ពីរ) ឆ្នាំ ក្រោយពេលចូលជាធរមាន។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី.....ខែ.....ឆ្នាំ២០២....
នាសម័យប្រជុំរដ្ឋសភាលើកទី.....នីតិកាលទី៧។
ថ្ងៃ.....ខែ.....ឆ្នាំ..... ព.ស.២៥.....
រាជធានីភ្នំពេញ ថ្ងៃទី.....ខែ.....ឆ្នាំ២០២....

ប្រធានរដ្ឋសភា

ឧបសម្ព័ន្ធនៃច្បាប់ស្តីពីកិច្ចការពារទិន្នន័យបុគ្គល

សង្ខាតុក្រម

១	ការធ្វើកូដនីយកម្ម Encryption	ការបំប្លែងព័ត៌មានឬទិន្នន័យទៅជាកូដពិសេសណាមួយដែលគេមិនអាចយល់ឬប្រើប្រាស់បាន។
២	ការធ្វើប្រព្រឹត្តកម្ម Processing	សំដៅដល់ប្រតិបត្តិការណាមួយ ឬសំណុំនៃប្រតិបត្តិការដែលអាចអនុវត្តបានលើទិន្នន័យបុគ្គល ទោះដោយមធ្យោបាយស្វ័យប្រវត្តិកម្មឬមិនស្វ័យប្រវត្តិកម្មក៏ដោយ រួមមានជាអាទិ៍ ការប្រមូល ការកត់ត្រា ការរៀបចំ ការរក្សាទុក ការកែប្រែ ការទាញយក ការប្រើប្រាស់ ការលាតត្រដាងដោយការបញ្ជូន ការផ្សព្វផ្សាយ ការលុប និងការបំផ្លាញចោល។
៣	ការធ្វើរហស្សនាមកម្ម Pseudonymization	សំដៅដល់ការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលតាមរបៀបដែលមិនអាចកំណត់អត្តសញ្ញាណប្រធានទិន្នន័យបាន។
៤	ការបែកធ្លាយទិន្នន័យបុគ្គល Data breach	សំដៅដល់ឧប្បត្តិហេតុដែលទិន្នន័យបុគ្គលត្រូវបានអាក់សេសលាតត្រដាង ឬលួចដោយគ្មានការអនុញ្ញាត។
៥	ការយល់ព្រម Consent	សំដៅដល់ការសម្តែងឆន្ទៈរបស់ប្រធានទិន្នន័យយល់ព្រមឱ្យមានការធ្វើប្រព្រឹត្តកម្មទិន្នន័យរបស់ខ្លួនផ្អែកតាមបទប្បញ្ញត្តិមាត្រា៨ នៃច្បាប់នេះ។
៦	ការយល់ព្រមច្បាស់លាស់ Explicit Consent	សំដៅដល់ការយល់ព្រមជាលាយលក្ខណ៍អក្សរ ឬ តាមកំណត់ត្រាអេឡិចត្រូនិក ដែលអាចយកមកធ្វើជាមូលដ្ឋានក្នុងការបង្ហាញកស្តុតាងបាន នៅពេលមានការជំទាស់ពីប្រធានទិន្នន័យ។
៧	ការលុបអត្តសញ្ញាណទិន្នន័យ Data anonymization	សំដៅដល់ដំណើរការនៃការបម្លែងទិន្នន័យបុគ្គល តាមមធ្យោបាយដែលរូបវន្តបុគ្គលនោះលែងត្រូវបានគេកំណត់អត្តសញ្ញាណ។ មានន័យថាការលុបព័ត៌មានទាំងស្រុងពាក់ព័ន្ធនឹងអត្តសញ្ញាណបុគ្គល ដែលសូម្បីតែបុគ្គលគ្រប់គ្រងទិន្នន័យ ឬបុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យក៏មិនអាចកំណត់អត្តសញ្ញាណរូបវន្តបុគ្គលនោះបានដែរ។
៨	ខ្វះសមត្ថភាពតាមផ្លូវច្បាប់ Legally Incapable	សំដៅដល់ស្ថានភាពរបស់រូបវន្តបុគ្គលដែលមិនអាចធ្វើការសម្រេចចិត្ត ឬធ្វើសកម្មភាពតាមផ្លូវច្បាប់មានជាអាទិ៍ ករណីអាយុមិនគ្រប់ (អនីតិជន) ករណីបាត់បង់សមត្ថភាពផ្លូវចិត្ត ឬការហាមឃាត់ដោយច្បាប់។

៩	គណៈគ្រប់គ្រង ឬថ្នាក់ដឹកនាំជាន់ខ្ពស់ Management Board or Senior Executive	សំដៅដល់ក្រុមប្រឹក្សាភិបាល នាយកប្រតិបត្តិ ប្រធាននៃក្រុមហ៊ុន ឬអង្គភាព ឬប្រធានផ្នែកដែលទទួលខុសត្រូវកិច្ចការគ្រប់គ្រងទិន្នន័យបុគ្គល។
១០	គោលការណ៍ណែនាំរួមស្តីពីកិច្ចការពារទិន្នន័យបុគ្គល Common Guidelines on Personal Data Protection	សំដៅដល់វិធានគ្រប់គ្រងទិន្នន័យបុគ្គល ដែលកំណត់លក្ខខណ្ឌអប្បរមា សម្រាប់បុគ្គលគ្រប់គ្រងទិន្នន័យ និងបុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ។
១១	គោលការណ៍ណែនាំបន្ថែមស្តីពីកិច្ចការពារទិន្នន័យបុគ្គលតាមវិស័យ Supplementary Guidelines for Sectoral Personal Data Protection	សំដៅដល់វិធានបន្ថែមស្តីពីការគ្រប់គ្រងទិន្នន័យបុគ្គលតាមវិស័យ សម្រាប់បុគ្គលគ្រប់គ្រងទិន្នន័យ និងបុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ ដែលរៀបចំដោយក្រសួង ស្ថាប័នទទួលបន្ទុកតាមវិស័យក្នុងករណីដែលលក្ខខណ្ឌអប្បរមាដែលកំណត់នៅក្នុងគោលការណ៍ណែនាំរួមស្តីពីកិច្ចការពារទិន្នន័យបុគ្គលមិនគ្រប់គ្រាន់សម្រាប់វិស័យនីមួយៗ។
១២	ទិន្នន័យបុគ្គលរសើបយិត Sensitive personal data	សំដៅដល់ទិន្នន័យបុគ្គលដែលបង្ហាញពីប្រភពដើមនៃជាតិសាសន៍ ទស្សនៈនយោបាយ ជំនឿសាសនាឬទស្សនវិជ្ជា ឬសមាជិកភាពក្នុងសហជីព ទិន្នន័យជីវមាត្រ ទិន្នន័យសេនេទិច ទិន្នន័យសុខភាព និងទិន្នន័យពាក់ព័ន្ធនឹងជីវិតផ្លូវភេទ ឬនិន្នាការភេទរបស់រូបវន្តបុគ្គល។
១៣	ទិន្នន័យបុគ្គល Personal data	សំដៅដល់ព័ត៌មានដែលពាក់ព័ន្ធនឹងរូបវន្តបុគ្គល ដែលកំណត់អត្តសញ្ញាណ ឬអាចកំណត់អត្តសញ្ញាណរូបវន្តបុគ្គលនោះបាន។ ព័ត៌មានដែលពាក់ព័ន្ធនឹងរូបវន្តបុគ្គល មានជាអាទិ៍ អត្តសញ្ញាណ (ឈ្មោះ លេខអត្តសញ្ញាណកម្ម ទិន្នន័យទីតាំង) អត្តសញ្ញាណអនឡាញ (អាសយដ្ឋានអាយភី អាសយដ្ឋានអ៊ីម៉ែល និងឈ្មោះគណនី) និងព័ត៌មានជាក់លាក់ណាមួយឬច្រើនអំពីអត្តសញ្ញាណរាងកាយ សរីរវិទ្យា សេនេទិច ផ្លូវចិត្ត សេដ្ឋកិច្ច វប្បធម៌ ឬសង្គមរបស់បុគ្គលនោះ។
១៤	ទិន្នន័យជីវមាត្រ Biometric data	សំដៅដល់ទិន្នន័យបុគ្គលដែលជាលទ្ធផលនៃការធ្វើប្រព្រឹត្តកម្មបច្ចេកទេសពាក់ព័ន្ធនឹងកាយសម្បទា សរីរវិទ្យា ឬ ចរិតលក្ខណៈនៃរូបវន្តបុគ្គលដែលអាចកំណត់អត្តសញ្ញាណរូបវន្តបុគ្គលបាន។ ឧទាហរណ៍៖ រូបភាពផ្ទៃមុខ ឬស្នាមក្រយៅដៃ។
១៥	**ទិន្នន័យសេនេទិច** Genetic data	សំដៅដល់ទិន្នន័យបុគ្គលដែលពាក់ព័ន្ធមតកជន ឬលក្ខណៈនៃហ្សែននៃរូបវន្តបុគ្គលដែលអាចកំណត់អត្តសញ្ញាណរូបវន្តបុគ្គលបាន។

១៦	ទិន្នន័យសុខភាព Data concerning health	សំដៅដល់ទិន្នន័យពាក់ព័ន្ធនឹងកាយសម្បទា សុខភាពខួរក្បាលនៃរូបវន្តបុគ្គលដូចជា ព័ត៌មានដែលពាក់ព័ន្ធនឹងស្ថានភាពសុខភាពរបស់រូបវន្តបុគ្គលហើយព័ត៌មាននោះអាចកំណត់អត្តសញ្ញាណរូបវន្តបុគ្គលបាន។
១៧	បទបញ្ជាផ្ទៃក្នុងស្តីពីកិច្ចការពារទិន្នន័យបុគ្គល Internal Regulations on Personal Data Protection	សំដៅដល់វិធានស្តីពីកិច្ចការពារទិន្នន័យបុគ្គលដែលបង្កើតដោយបុគ្គលគ្រប់គ្រងទិន្នន័យនិងបុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ។
១៨	ប្រធានទិន្នន័យ Data subject	សំដៅដល់រូបវន្តបុគ្គលដែលត្រូវបានកំណត់អត្តសញ្ញាណឬអាចត្រូវបានកំណត់អត្តសញ្ញាណបាន។
១៩	ប្រព័ន្ធផ្សព្វផ្សាយប្រពៃណី Traditional Media	សំដៅដល់ប្រព័ន្ធផ្សព្វផ្សាយដែលកើតមុន សម័យអ៊ីនធឺណិត ដូចជា កាសែត ទស្សនាវដ្តី សៀវភៅអាន វិទ្យុ ទូរទស្សន៍ និងភាពយន្ត។
២០	ប្រព័ន្ធផ្សព្វផ្សាយបែបថ្មី New Media	សំដៅដល់ប្រព័ន្ធផ្សព្វផ្សាយបែបថ្មី ដែលកំណត់អ្វីៗទាក់ទងនឹងអ៊ីនធឺណិតដោយមានអន្តរកម្មរវាងអ្នកផ្សព្វផ្សាយ និងអ្នកប្រើប្រាស់ឬអ្នកប្រើប្រាស់ និងអ្នកប្រើប្រាស់នូវបច្ចេកវិទ្យាថ្មី ទាំងរូបភាព និងសំឡេង។ និយមន័យរបស់ពាក្យនេះប្រែប្រួលឥតឈប់ឈរ តាមការវិវត្តវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាព័ត៌មានទាំងអាណាឡូក (Analogue) និងឌីជីថល (Digital) ដូចជា Facebook YouTube បណ្តាញទំនាក់ទំនងឯកសារ...។ល។
២១	**ប្រព័ន្ធឯកសារ** Filing system	សំដៅដល់ប្រព័ន្ធបណ្តុំនៃទិន្នន័យបុគ្គលដែលអាចអាក់សេសបានតាមលក្ខខណ្ឌជាក់លាក់ណាមួយ។
២២	**បុគ្គល** Person	សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គល។
២៣	**បុគ្គលគ្រប់គ្រងទិន្នន័យ** Data controller	សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលកំណត់អំពីគោលបំណងនិងមធ្យោបាយនៃការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គល។ នីតិបុគ្គលដែលត្រូវចាត់ទុកថាជាបុគ្គលគ្រប់គ្រងទិន្នន័យក្នុងច្បាប់នេះរួមមាននីតិបុគ្គលឯកជន គ្រឹះស្ថានសាធារណៈរដ្ឋបាល ឬសហគ្រាសសាធារណៈ ដោយមិនរាប់បញ្ចូលអាជ្ញាធរសាធារណៈដែលបំពេញមុខងារក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឡើយ។ បុគ្គលគ្រប់គ្រងទិន្នន័យដែលជាអាជ្ញាធរសាធារណៈដែលត្រូវស្ថិតនៅក្រោមការគ្រប់គ្រងដោយច្បាប់នេះផ្អែកតាមការសម្រេចរបស់រាជរដ្ឋាភិបាលឬដោយបញ្ញត្តិដោយឡែក។

២៤	**បុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ** Data processor	សំដៅដល់រូបវន្តបុគ្គល នីតិបុគ្គលឯកជន គ្រឹះស្ថានសាធារណៈ រដ្ឋបាល ឬសហគ្រាសសាធារណៈដែលធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលក្នុងនាមបុគ្គលគ្រប់គ្រងទិន្នន័យតាមរយៈកិច្ចសន្យា។
២៥	**មន្ត្រីកិច្ចការពារទិន្នន័យបុគ្គល** Data Protection Officer	សំដៅដល់រូបវន្តបុគ្គលដែលត្រូវបានចាត់តាំងឱ្យជួយអនុលោមភាពនៃការធ្វើប្រព្រឹត្តកម្មទិន្នន័យបុគ្គលដែលកំណត់ដោយច្បាប់នេះ។ រូបវន្តបុគ្គលនោះអាចជាកម្មករនិយោជិត ឬអ្នកតំណាងដោយអាណត្តិ។ នៅពេលច្បាប់នេះចូលជាធរមានមន្ត្រីកិច្ចការពារទិន្នន័យបុគ្គលត្រូវមានវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈកិច្ចការពារទិន្នន័យបុគ្គល។
២៦	វិធានការបុរេជម្រើសនៃកិច្ចការពារទិន្នន័យបុគ្គល Data protection by default	សំដៅដល់អភិក្រមដែលជាកាតព្វកិច្ចសម្រាប់បុគ្គលគ្រប់គ្រងទិន្នន័យក្នុងការកំណត់ជាស្វ័យប្រវត្តក្នុងឧបករណ៍ ឬប្រព័ន្ធដែលបង្កលក្ខណៈងាយស្រួលដល់អ្នកប្រើប្រាស់អាចគ្រប់គ្រងឯកជនភាពរបស់ខ្លួននៅពេលប្រើប្រាស់ ឬទទួលសេវាតាមប្រព័ន្ធអេឡិចត្រូនិក។
២៧	វិធានការនិម្មាបនកម្មបច្ចេកទេសនៃកិច្ចការពារទិន្នន័យបុគ្គល Data protection by design	សំដៅដល់អភិក្រមដែលជាកាតព្វកិច្ចសម្រាប់ការធ្វើនិម្មាបនកម្មប្រព័ន្ធដោយដាក់បញ្ចូលវិធានការបច្ចេកទេស និងវិធានការគ្រប់គ្រងទិន្នន័យបុគ្គល ចាប់តាំងពីពេលដំបូងជាជាងបន្ថែមវិធានការនៅពេលក្រោយ។ ការកំណត់អភិក្រមនេះមានគោលបំណងការពារហានិភ័យនៃការបែកធ្លាយទិន្នន័យ។
២៨	សកម្មភាពផ្ទាល់ខ្លួនឬសកម្មភាពពាក់ព័ន្ធនឹងគ្រួសារ Personal or household activities	សំដៅដល់សកម្មភាពទាក់ទងផ្ទាល់នឹងរូបវន្តបុគ្គលការងារផ្ទះ ឬគ្រួសារ ហើយមិនមែនជាសកម្មភាពអាជីព ឬអាជីវកម្ម។
២៩	អង្គភាពសារព័ត៌មាន News entity	សំដៅដល់ក្រុមបុគ្គល ឬនីតិបុគ្គល ដែលផ្សព្វផ្សាយព័ត៌មានជាសាធារណៈ តាមប្រព័ន្ធផ្សព្វផ្សាយប្រពៃណី និង/ឬបែបថ្មី។
៣០	អាជ្ញាធរសាធារណៈ Public Authority	សំដៅដល់ក្រសួងស្ថាប័ននៃអង្គការនីតិប្រតិបត្តិ អង្គការនីតិប្បញ្ញត្តិ និងអង្គការតុលាការរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពសាធារណៈដែលប្រហាក់ប្រហែល។
៣១	អ្នកតំណាងរបស់បុគ្គលគ្រប់គ្រងទិន្នន័យនិងបុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ Representative of data controller and data processor	សំដៅដល់អ្នកតំណាងដោយអាណត្តិរបស់បុគ្គលគ្រប់គ្រងទិន្នន័យ ឬបុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ។ បុគ្គលនោះអាចជាមេធាវី ឬជាបុគ្គលដែលទទួលបានសិទ្ធិស្របច្បាប់ពីបុគ្គលគ្រប់គ្រងទិន្នន័យ ឬបុគ្គលធ្វើប្រព្រឹត្តកម្មទិន្នន័យ។